ព្រះរាជាណាចក្រកម្ពុជា

ជាតិ | សាសនា | ព្រះមហាក្សត្រ

# វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ កម្ពុជា

## ២០២១



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
គេហទំព័រ៖ https://www.misti.gov.kh

ការបោះពុម្ពជាសៀវភៅអេឡិចត្រូនិកលើកទី១៖ ២០២២
លេខចុះបញ្ជីរបស់បណ្ណាល័យជាតិ
ISBN: 978-9924-9556-6-5 (ភាសាខ្មែរ)
ISBN: 978-9924-9556-5-8 (ភាសាអង់គ្លេស)

© ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ២០២២

របាយការណ៍នេះជាកម្មសិទ្ធិរបស់អ្នកនិពន្ធ និងរក្សាសិទ្ធិគ្រប់យ៉ាងដោយ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ គ្មានផ្នែកណាមួយនៃរបាយការណ៍នេះអាចត្រូវបានផលិតឡើងវិញ ចែកចាយ ឬបញ្ជូនតាមទម្រង់ ឬមធ្យោបាយណាមួយ ឬរក្សាទុកនៅក្នុងប្រព័ន្ធទិន្នន័យ ឬប្រព័ន្ធដែលអាចទាញយកបានដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីម្ចាស់កម្មសិទ្ធិបញ្ញាឡើយ។ អ្នកបោះពុម្ពផ្សាយ អ្នករៀបរៀង និងនិពន្ធនាយកសន្មតថាអនុសាសន៍ និងព័ត៌មាននៅក្នុងរបាយការណ៍នេះមានភាពជាក់លាក់និងត្រឹមត្រូវនៅថ្ងៃនៃការបោះពុម្ពផ្សាយ។ ទាំងអ្នកបោះពុម្ពផ្សាយ អ្នករៀបរៀង ឬនិពន្ធនាយក ពុំធានានូវការបង្ហាញឬការបញ្ជាក់ទាក់ទងនឹងព័ត៌មាននិងទិន្នន័យយោងដែលមាននៅក្នុងរបាយការណ៍នេះ ឬកំហុសឆ្គងឬការលុបណាមួយដែលអាចកើតឡើងដោយប្រការណាមួយនោះទេ។

អាសយដ្ឋានរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍៖ អគារលេខ ៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ១២០២០៣ ព្រះរាជាណាចក្រកម្ពុជា

# អារម្ភកថា

វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (**វ.ប.ន.**) ត្រូវបានកំណត់ជាផ្នែកស្នូលនៃការអភិវឌ្ឍជាតិដើម្បីសម្រេចបានចក្ខុវិស័យកម្ពុជានៅឆ្នាំ២០៣០ និង២០៥០ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ ដោយមានឆន្ទៈខ្ពស់លើការរៀបចំរចនាសម្ព័ន្ធ **វ.ប.ន.** ពីរាជរដ្ឋាភិបាលកម្ពុជា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (**ឧ.វ.ប.ន.**) និងក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (**ក.ជ.វ.ប.ន.**) ត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួលនិងតម្រង់ទិសលើរាល់កិច្ចការដែលមានលក្ខណៈប្រទាក់ក្រឡា និងអន្តរក្រសួង-ស្ថាប័ន។ ការអនុម័តគោលនយោបាយជាតិស្តីពី **វ.ប.ន.** ២០២០-២០៣០ ដោយរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ២០១៩ ជាមូលដ្ឋានគ្រឹះដំបូងនៃកិច្ចខិតខំប្រឹងប្រែងដើម្បីលើកតម្កើងប្រព័ន្ធអេកូឡូស៊ី **វ.ប.ន.** របស់កម្ពុជា។ ជាងនេះទៅទៀត អគ្គនាយកដ្ឋាន **វ.ប.ន.** នៃក្រសួង **ឧ.វ.ប.ន.** បានរៀបចំផែនទីបង្ហាញផ្លូវ **វ.ប.ន.កម្ពុជា២០៣០** ដែលរំលេចយ៉ាងច្បាស់ពីទិសដៅយុទ្ធសាស្ត្រសម្រាប់ក្រសួង និងស្ថាប័នពាក់ព័ន្ធដើម្បីអនុវត្តសកម្មភាពសម្រាប់រយៈពេលខ្លី និងមធ្យមរហូតដល់ឆ្នាំ២០៣០។ ផែនទីបង្ហាញផ្លូវ **វ.ប.ន. កម្ពុជា ២០៣០** ដែលជាឯកសារបង្ហាញពីការអនុវត្តគោលនយោបាយជាតិស្តីពី **វ.ប.ន.** បានកំណត់គោលដៅច្បាស់លាស់ តាមរយៈការដាក់ចេញនូវសំណុំសកម្មភាពសំខាន់ៗដោយមានពេលវេលាកំណត់ និងចំណុចដៅជាក់លាក់ ដើម្បីសម្រេចឱ្យបាននៅឆ្នាំ២០៣០។ ឯកសារនេះបង្ហាញតួនាទីច្បាស់លាស់របស់ក្រសួង **ឧ.វ.ប.ន.** ដើម្បីពិនិត្យពិច័យ និងសម្របសម្រួលរាល់ការអនុវត្តគោលនយោបាយជាតិស្តីពី **វ.ប.ន** នៅតាមបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ។

ទន្ទឹមគ្នានឹងចក្ខុវិស័យ ក៏ដូចជាគោលដៅដែលបានកំណត់ក្នុងផែនទីបង្ហាញផ្លូវ **វ.ប.ន.** កម្ពុជា ២០៣០ របាយការណ៍នេះផ្តល់បន្ថែមទៀតនូវទិដ្ឋភាពទូទៅនិងបច្ចុប្បន្នភាពចុងក្រោយនៃក្របខ័ណ្ឌគោលនយោបាយនិងច្បាប់ និងវឌ្ឍនភាពទាក់ទងនឹងវិស័យ **វ.ប.ន.** ត្រឹមឆ្នាំ២០២១។ ផ្នែកផ្គត់ផ្គង់ និងតម្រូវការនៃវិស័យ **វ.ប.ន.** ដែលជាផ្នែកសំខាន់នៃប្រព័ន្ធនវានុវត្តន៍ជាតិត្រូវបានបរិយាយយ៉ាងទូលំទូលាយក្នុងរបាយការណ៍នេះ។ ខ្ញុំសង្ឃឹមថារបាយការណ៍នេះនឹងផ្តល់ជាប្រយោជន៍ដល់សាធារណជនគ្រប់ស្រទាប់ជាន់ថ្នាក់ជាអាទិ៍៖ អ្នកធ្វើគោលនយោបាយ អ្នកសិក្សាស្រាវជ្រាវវិស័យឯកជន និងដៃគូអភិវឌ្ឍន៍ជាដើមក្នុងប្រតិបត្តិការកិច្ចការរបស់ខ្លួន និងយល់ដឹងពីស្ថានភាពក្នុងវិស័យ **វ.ប.ន.** នៃព្រះរាជាណាចក្រកម្ពុជា។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមលេខាធិការដ្ឋាននៃក.ជ.វ.ប.ន. ជាពិសេសក្រុមអ្នករៀបរៀង និងក្រុមនិពន្ធនាយកដែលបានចែករំលែកនិងរៀបចំឱ្យមានរបាយការណ៍ **វ.ប.ន.** ឆ្នាំ២០២១ ដ៏មានតម្លៃនេះ។

ថ្ងៃពុធ ៤ កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០២២

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា**

**និងនវានុវត្តន៍**

**និងជាប្រធានក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា**

**និងនវានុវត្តន៍**

***កិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ***

| អ្នករៀបរៀង | |
|---|---|
| លោកបណ្ឌិត **ហ៊ុល សៀងហេង** | ប្រធាន |
| លោកបណ្ឌិត **គួក ហ្វីដេរ៉ូ** | សមាជិក |
| លោកបណ្ឌិត **សៀវ សុខលី** | សមាជិក |
| លោក **ចិន សុវណ្ណា** | សមាជិក |
| លោក **ប៊ិ សំណាង** | សមាជិក |
| កញ្ញា **តាំង ចាន់រស្មី** | សមាជិក |
| លោក **សឿ ជំនិត** | សមាជិក |
| លោក **ស៊ាន រិទ្ធី** | សមាជិក |
| លោក **ខន សុខេង** | សមាជិក |
| លោក **អឿម សាវ៉ាន់** | សមាជិក |

| ក្រុមនិពន្ធនាយក | |
|---|---|
| លោកបណ្ឌិត **សៀវ សុខលី** | ប្រធាននិពន្ធនាយក |
| លោក **ប៊ិ សំណាង** | អនុប្រធាននិពន្ធនាយក |
| លោកបណ្ឌិត **ហ៊ុល សៀងហេង** | និពន្ធនាយក |

**បោះពុម្ពផ្សាយ**

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

# មាតិកា


**អារម្ភកថា** ..... i
**មាតិកា** ..... iii
**បញ្ជីអក្សរកាត់ និងពាក្យគន្លឹះ** ..... v
**បញ្ជីរូបភាព** ..... viii
**១. សេចក្តីផ្តើម** ..... ១
១.១. សាវតារ ..... ១
១.២. គោលបំណង ..... ៦
១.៣. វិធីសាស្ត្រនិងវិសាលភាព ..... ៦
**២. តម្រូវការវិស័យ វ.ប.ន. ក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ច** ..... ៦
**៣. ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ** ..... ៩
របៀបវារៈស្រាវជ្រាវជាតិ ..... ៩
ការសង្កតសកលនៃលិខិតូករណ៍គោលនយោបាយ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ហ្វូស្ទីន) ..... ៩
ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន ..... ១០
ច្បាប់វិនិយោគថ្មី ..... ១០
ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ..... ១១
ច្បាប់ផ្ទេរបច្ចេកវិទ្យា ..... ១២
ច្បាប់ស្តីពីស្តង់ដារ ..... ១២
ច្បាប់ស្តីពីមាត្រាសាស្ត្រ ..... ១៣
ច្បាប់កម្មសិទ្ធិបញ្ញា ..... ១៣
**៤. ធនធានមនុស្ស** ..... ១៤
២.១. កម្រិតមធ្យមសិក្សាទុតិយភូមិ ..... ១៤
៤.២. កម្រិតឧត្តមសិក្សា ..... ១៨
៤.៣. កម្រិតក្រោយឧត្តមសិក្សា ..... ២១
៤.៤. ការអប់រំក្រៅប្រព័ន្ធ ..... ២៤
៤.៥. ទិន្នន័យធនធានមនុស្សជាអ្នកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ..... ២៥
**៥. វឌ្ឍនភាពនៃវិស័យ វ.ប.ន** ..... ២៧
៥.១. គម្រោង/កិច្ចសហការក្នុងវិស័យ វ.ប.ន. ..... ២៧

៥.២  កិច្ចសហការជាមួយអ្នកពាក់ព័ន្ធ ........ ២៨
៥.៣. ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ........ ២៩
៥.៤. ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផែនទីបង្ហាញផ្លូវ វ.ប.ន.កម្ពុជា ២០៣០ ........ ៣០
**៦. សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ........ ៣២
**ឯកសារយោង** ........ ៣៤

## បញ្ជីអក្សរកាត់ និងពាក្យគន្លឹះ

| | | |
|---|---|---|
| ASEAN (អាស៊ាន) | : | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| AVI | : | វិទ្យាស្ថានចក្ខុវិស័យអាស៊ី |
| CCC | : | សភាពាណិជ្ជកម្មកម្ពុជា |
| CCFTA | : | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន |
| CDC | : | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CKFTA | : | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ |
| COSTI | : | គណៈកម្មាធិការផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| DGHE | : | អគ្គនាយកដ្ឋានឧត្តមសិក្សា |
| D/MIE | : | នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ |
| EPO | : | ការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប |
| FDI | : | ការវិនិយោគដោយផ្ទាល់ពីបរទេស |
| GDP | : | ផលិតផលក្នុងស្រុកសរុប |
| GD/STI | : | អគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| GIS | : | ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ |
| GO-SPIN (ហ្គោស្ពីន) | : | គម្រោងហ្គោស្ពីន |
| GPS | : | ប្រព័ន្ធកំណត់ទីតាំងសាកល |
| HEIs | : | គ្រឹះស្ថានឧត្តមសិក្សា |
| HEIP | : | គម្រោងកែលម្អការអប់រំឧត្តមសិក្សា |
| ICT | : | បច្ចេកវិទ្យាទំនាក់ទំនង និងព័ត៌មាន |
| IPOS | : | ការិយាល័យកម្មសិទ្ធិបញ្ញានៃប្រទេសសិង្ហបុរី |
| ISCED | : | ស្តង់ដារអន្តរជាតិនៃចំណាត់ថ្នាក់ការសិក្សា |
| JPO | : | ការិយាល័យប្រកាសនីយបត្រតក្កកម្មជប៉ុន |
| KPI | : | សូចនាករសមិទ្ធកម្មគន្លឹះ |
| LDC | : | ប្រទេសមានការអភិវឌ្ឍតិចតួច |
| LiDAR | : | បច្ចេកវិទ្យាឡៃដារ |
| M&E | : | ការត្រួតពិនិត្យ និងវាយតម្លៃ |
| MAFF | : | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MCFA | : | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |

| | | |
|---|---|---|
| MISTI | : | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| MLMUPC | : | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MLVT | : | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoE | : | ក្រសួងបរិស្ថាន |
| MFAIC | : | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| MoH | : | ក្រសួងសុខាភិបាល |
| MoI | : | ក្រសួងមហាផ្ទៃ |
| MoInfo | : | ក្រសួងព័ត៌មាន |
| MoJ | : | ក្រសួងយុត្តិធម៌ |
| MoP | : | ក្រសួងផែនការ |
| MoT | : | ក្រសួងទេសចរណ៍ |
| MoWRAM | : | ក្រសួងធនធានទឹក និងឧតុនិយម |
| MoEYS | : | ក្រសួងអប់រំ យុវជន និងកីឡា |
| MPTC | : | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| MPWT | : | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| MRD | : | ក្រសួងអភិវឌ្ឍន៍ជនបទ |
| NCSTI | : | ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| NDESC | : | ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និងសង្គមឌីជីថល |
| NIS | : | ប្រព័ន្ធនវានុវត្តន៍ជាតិ |
| NISTI | : | វិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| OCM | : | ទីស្តីការគណៈរដ្ឋមន្ត្រី |
| PPP | : | ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន |
| PCT | : | សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម |
| QIP | : | គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ |
| R&D | : | ការស្រាវជ្រាវ និងអភិវឌ្ឍន៍ |
| RGC | : | រាជរដ្ឋាភិបាលកម្ពុជា |
| RCEP | : | កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ |
| SIPO | : | ការិយាល័យកម្មសិទ្ធិបញ្ញារបស់រដ្ឋ |
| SMEs | : | សហគ្រាសធុនតូច និងមធ្យម |
| SNEC | : | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| STEM (ស្ទែម) | : | វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា |

| | | |
|---|---|---|
| SSCA | : | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល |
| S&T | : | វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា |
| STI | : | វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| TVET (ធីវេត) | : | ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| UNCTAD | : | សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍន៍ |
| UNESCAP | : | គណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក |
| UNESCO (យូណេស្កូ) | : | អង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ |
| WIPO | : | អង្គការកម្មសិទ្ធិបញ្ញាពិភពលោក |
| WTO | : | អង្គការពាណិជ្ជកម្មពិភពលោក |

## បញ្ជីរូបភាព


រូបភាពទី ១.១៖ ក្របខ័ណ្ឌប្រព័ន្ធនវានុវត្តន៍ជាតិ (Kuhlmann និង Arnold, ២០០១) ............................៣

រូបភាពទី ១.២៖ សេចក្តីសង្ខេបនៃផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០(MISTI, ២០២១) ..................៣

រូបភាពទី ១.៣៖ ប្រព័ន្ធនវានុវត្តន៍ជាតិកម្ពុជា ក) ភាពខ្លាំង, ខ) ភាពខ្សោយ (MISTI & UNESCAP, ២០២១)........៥

រូបភាពទី ២.១៖ របាយការងារបែងចែកទៅតាមវិស័យនានា (ប្រភព៖ World Bank, ២០២១) ............... ៨

រូបភាពទី ៤.១៖ ចំនួនសិស្សនៅកម្រិតវិទ្យាល័យ........................................................................ ១៥

រូបភាពទី ៤.២៖ ចំនួនសមាមាត្រសិស្សផ្នែកស្ទែមនិងមិនមែនស្ទែមក្នុងថ្នាក់ទី ១១ គិតជាភាគរយ............ ១៦

រូបភាពទី ៤.៣៖ ចំនួនសមាមាត្រសិស្សស្រីផ្នែកស្ទែមក្នុងថ្នាក់ទី ១១ គិតជាភាគរយ ............................... ១៦

រូបភាពទី ៤.៤៖ ចំនួនសមាមាត្រសិស្សផ្នែកស្ទែមនិងមិនមែនស្ទែមក្នុងថ្នាក់ទី ១២ គិតជាភាគរយ ............១៧

រូបភាពទី ៤.៥៖ ចំនួនសមាមាត្រសិស្សស្រីផ្នែកស្ទែមក្នុងថ្នាក់ទី ១២ គិតជាភាគរយ ...............................១៧

រូបភាពទី ៤.៦៖ ចំនួនសិស្សដែលបានបញ្ចប់ការសិក្សាថ្នាក់ទី ១២........................................................ ១៨

រូបភាពទី ៤.៧៖ ចំនួននិស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររង (ប្រភពទិន្នន័យ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)............................................................................................. ១៩

រូបភាពទី ៤.៨៖ ចំនួននិស្សិតដែលកំពុងសិក្សាក្នុងថ្នាក់បរិញ្ញាបត្រ........................................................ ១៩

រូបភាពទី ៤.៩៖ ចំនួននិស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ................................................. ២០

រូបភាពទី ៤.១០៖ ចំនួននិស្សិតផ្នែកស្ទែមដែលកំពុងសិក្សានិងបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ..........២១

រូបភាពទី ៤.១១៖ ចំនួននិស្សិតដែលកំពុងសិក្សាថ្នាក់ក្រោយឧត្តមសិក្សាចាប់ពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០២០...២២

រូបភាពទី ៤.១២៖ ចំនួននិស្សិតផ្នែកស្ទែម និងចំនួននិស្សិតសរុបកំពុងសិក្សាក្នុងថ្នាក់ក្រោយឧត្តមសិក្សា...២៣

រូបភាពទី ៤.១៣៖ ចំនួននិស្សិតស្រីនិងចំនួននិស្សិតផ្នែកស្ទែមសរុបកំពុងសិក្សាក្នុងថ្នាក់ក្រោយឧត្តមសិក្សា......២៣

រូបភាពទី ៤.១៤៖ ចំនួននិស្សិតដែលបានបញ្ចប់ការសិក្សាក្នុងថ្នាក់ក្រោយឧត្តមសិក្សាចាប់ពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០២០................................................................................................................... ២៤

រូបភាពទី ៤.១៥៖ ចំនួនសិស្សស្រីនិងសរុបដែលបានបញ្ចប់ការសិក្សាការអប់រំក្រៅប្រព័ន្ធ........................ ២៥

រូបភាពទី ៤.១៦៖ ការប្រៀបធៀបកម្រិតសញ្ញាបត្រ និងភេទ ................................................................ ២៦

រូបភាពទី ៤.១៧៖ ធនធានមនុស្សអ្នកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាតាមឯកទេស ......................................២៧

រូបភាពទី ៥.១៖ ចំនួនគម្រោង/កិច្ចសហការដែលទាក់ទងនឹង វ.ប.ន.។ លេខសូន្យមានន័យថាក្រសួងមិនមានគម្រោង/កិច្ចសហការក្នុងវិស័យ វ.ប.ន. ឬមិនបានផ្តល់ព័ត៌មាន។............................................................ ២៨

រូបភាពទី ៥.២៖ ប្រភេទ និងស្ថានភាពនៃគម្រោង/កិច្ចសហការដែលពាក់ព័ន្ធនឹង វ.ប.ន.......................... ២៩

## ១. សេចក្តីផ្តើម

### ១.១. សាវតារ

ព្រះរាជាណាចក្រកម្ពុជាបានដាក់ឱ្យប្រើប្រាស់នូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ជារបៀបវារៈអភិវឌ្ឍន៍ជាតិចុងក្រោយបង្អស់។ យុទ្ធសាស្ត្រនេះផ្តោតសំខាន់លើកំណើនការងារ សមធម៌ និងប្រសិទ្ធភាព (RGC, ២០១៨)។ ជាក់ស្តែង ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាគឺជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។ **វ.ប.ន.** គឺជាមូលដ្ឋានសសរស្តម្ភមួយដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យដែលបានកំណត់នេះ។ រាជរដ្ឋាភិបាលបានរៀបចំរចនាសម្ព័ន្ធលើវិស័យ **វ.ប.ន.** ក្នុងក្រសួង **ឧ.វ.ប.ន.** ដូចបានបង្ហាញក្នុងព្រះរាជក្រឹត្យលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០។ បន្ថែមពីនេះ រចនាសម្ព័ន្ធនៃ **ក.ជ.វ.ប.ន.** ត្រូវបានបង្កើតឡើងដោយមានអគ្គនាយកដ្ឋាន **វ.ប.ន.** នៃក្រសួង **ឧ.វ.ប.ន.** ជាលេខាធិការដ្ឋាន ដើម្បីសម្របសម្រួល និងដឹកនាំការងារ **វ.ប.ន.** ក្នុងក្របខ័ណ្ឌអន្តរក្រសួង-ស្ថាប័ន។ ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ី **វ.ប.ន.** នៅក្នុងប្រទេសកម្ពុជាបានទទួលការចាប់អារម្មណ៍ពីសាធារណជន និងថ្នាក់ដឹកនាំជាន់ខ្ពស់ក្នុងការជំរុញបន្ថែមឱ្យប្រទេសកម្ពុជាឈានទៅដល់ចក្ខុវិស័យដែលបានកំណត់នៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។ ឧទាហរណ៍ «ការចូលរួមចំណែកអភិវឌ្ឍ ធនធានមនុស្ស តាមរយៈការផ្ទេរបច្ចេកវិទ្យា ចំណេះដឹង និងចំណេះធ្វើ ជាពិសេសការអភិវឌ្ឍជំនាញឌីជីថល ព្រមទាំងការលើកកម្ពស់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តាមរយៈការចូលរួមសហការជាមួយធុរកិច្ច និងវិនិយោគផ្ទាល់ពីបរទេសដែលជួយការកាត់បន្ថយគម្លាតឌីជីថល និងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលក្នុងតំបន់»។ នេះបើយោងតាមសេចក្តីដកស្រង់ប្រសាសន៍ក្នុងពិធីបិទកិច្ចប្រជុំកំពូលធុរកិច្ច និងវិនិយោគអាស៊ាន ឆ្នាំ២០២១ ក្រោមប្រធានបទ «ការកសាងអនាគតឌីជីថលប្រកបដោយចីរភាពរបស់យើង» នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

តាមគោលការណ៍ ប្រព័ន្ធនវានុវត្តន៍ជាតិ (NIS) មានមុខងារសំខាន់ក្នុងការវាយតម្លៃស្ថានភាពអភិវឌ្ឍន៍នៃប្រព័ន្ធអេកូឡូស៊ី **វ.ប.ន.**។ ការកំណត់សូចនាករច្បាស់លាស់គឺត្រូវតែបង្កើតឡើងតាំងពីដំបូង ដើម្បីធានាបាននូវភាពងាយស្រួលនៃការត្រួតពិនិត្យ និងវាយតម្លៃ (M&E)។ ការផ្គូផ្គងរវាងតម្រូវការ និងការផ្គត់ផ្គង់នៃវិស័យ **វ.ប.ន.** មានសារៈសំខាន់ណាស់ដែលត្រូវបានបង្កើតឡើងដោយមានក្របខ័ណ្ឌគោលនយោបាយនិងហេដ្ឋារចនាសម្ព័ន្ធគាំទ្រដូចបានបង្ហាញក្នុងរូបភាពទី ១.១។ ជាពិសេស គុណភាព និងបរិមាណធនធានមនុស្សផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម) ត្រូវមានគ្រប់គ្រាន់សម្រាប់វិស័យធុរកិច្ច តួយ៉ាងដូចជា ឧស្សាហកម្ម ឬសហគ្រាសធុនតូចនិងមធ្យម ដែលមានតម្រូវការកម្លាំងពលកម្មជំនាញកម្រិតខ្ពស់។

ការអនុម័តគោលនយោបាយជាតិស្តីពី **វ.ប.ន.** ឆ្នាំ២០២០-២០៣០ ដោយ **សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**ក្នុងឆ្នាំ២០១៩ គឺជាមូលដ្ឋានគ្រឹះដំបូងនៃការគាំទ្ររបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់ប្រព័ន្ធអេកូឡូស៊ី **វ.ប.ន.**។ ដោយមានការគាំទ្រជាបន្តបន្ទាប់ពីរាជរដ្ឋាភិបាល ផែនទី

បង្ហាញផ្លូវ **វ.ប.ន.** កម្ពុជា ២០៣០ ត្រូវបានដាក់ចេញជាយុទ្ធសាស្ត្រសម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ លើសកម្មភាពដែលត្រូវអនុវត្តក្នុងរយៈពេលខ្លី និងមធ្យមរហូតដល់ឆ្នាំ ២០៣០។ ផែនទីបង្ហាញផ្លូវ **វ.ប.ន.** កម្ពុជា ២០៣០ ដែលជាឯកសារបង្ហាញពីការអនុវត្តគោលនយោបាយជាតិស្តីពី **វ.ប.ន.** បានកំណត់គោលដៅច្បាស់លាស់ តាមរយៈការដាក់ចេញនូវសំណុំសកម្មភាពសំខាន់ៗដោយមានពេលវេលាកំណត់ និងចំណុចដៅជាក់លាក់ ដើម្បីសម្រេចឱ្យបាននៅឆ្នាំ២០៣០។ ផែនទីបង្ហាញផ្លូវនេះផ្តល់តួនាទីយ៉ាងច្បាស់លាស់ដល់ ក្រសួង **ឧ.វ.ប.ន.** ក្នុងការត្រួតពិនិត្យ និងសម្របសម្រួលការអនុវត្តគោលនយោបាយជាតិស្តីពី **វ.ប.ន.** ក្នុងក្របខ័ណ្ឌអន្តរក្រសួង។ ផែនទីបង្ហាញផ្លូវនេះ មានសសរស្តម្ភចំនួនប្រាំដែលមានសារៈសំខាន់ក្នុងការអនុវត្តគោលនយោបាយជាតិស្តីពី **វ.ប.ន.** (រូបភាពទី ១.២)។ ការពិពណ៌នាខ្លីអំពីសសរស្តម្ភសំខាន់ៗ ដែលត្រូវពង្រឹងទាំងនេះមានដូចខាងក្រោម៖

- **អភិបាលកិច្ច៖** ពង្រឹងសមត្ថកិច្ចរបស់ក្រសួង **ឧ.វ.ប.ន.** ដែលមាន **ក.ជ.វ.ប.ន.** ជាស្ថានប័នសម្របសម្រួលនិងណែនាំលើការងារ **វ.ប.ន.** ដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ។
- **មូលធនមនុស្ស៖** ធនធានមនុស្សផ្នែកស្នែមទាំងគុណភាព និងបរិមាណត្រូវតែផលិតឱ្យបាន សម្រាប់វិស័យអាទិភាពដើម្បីចូលរួមអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។
- **ការស្រាវជ្រាវ និងអភិវឌ្ឍន៍៖** ការវិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ត្រូវតែធ្វើឡើងឱ្យទាន់ពេលវេលាដើម្បីបង្កើតចំណេះដឹង សម្រាប់ផ្គត់ផ្គង់តម្រូវការដល់វិស័យសាធារណៈនិងឯកជន។
- **កិច្ចសហការ៖** ការបំបែកស៊ីឡូក្នុងចំណោមស្ថាប័នរាជរដ្ឋាភិបាល ស្ថាប័នសិក្សា និងវិស័យឯកជនជាការចាំបាច់ដើម្បីបង្កបរិយាកាសការងាររវាងគ្នានិងគ្នា ។
- **ប្រព័ន្ធអេកូឡូស៊ី៖** ប្រព័ន្ធអេកូឡូស៊ីសមស្របដែលមានការវិនិយោគទាំងក្នុងស្រុក និងពីបរទេសរួមគ្នាត្រូវតែបង្កើតឡើងដោយមានការបន្សីគ្នារវាងកម្លាំងពលកម្មដែលមានជំនាញគ្រប់គ្រាន់និងកម្រិតខ្ពស់ គោលនយោបាយវិនិយោគដែលមានភាពទាក់ទាញនិងហេដ្ឋារចនាសម្ព័ន្ធចាំបាច់។

ផែនទីបង្ហាញផ្លូវគូសបញ្ជាក់ពី សូចនាករសំខាន់ៗដែលត្រូវសម្រេចឱ្យបាន តាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាលត្រឹមឆ្នាំ ២០៣០។ សូចនាករសំខាន់ៗត្រឹមឆ្នាំ ២០៣០ ត្រូវបានសង្ខេបដូចមាននៅក្នុងរូបភាពទី ១.២។ ទោះបីជាសូចនាករដែលបានកំណត់ពោរពេញដោយមហិច្ឆតា ប៉ុន្តែវាមានភាពចាំបាច់ណាស់ក្នុងការធ្វើឱ្យសម្រេចបាននូវចក្ខុវិស័យប្រកបដោយមហិច្ឆិតានេះដោយប្រែក្លាយកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។ ព័ត៌មានជាក្រាហ្វិកនៃផែនទីបង្ហាញផ្លូវនេះ ដូចមានក្នុងរូបភាពទី ១.២ បង្ហាញយ៉ាងច្បាស់នូវកិច្ចខិតខំប្រឹងប្រែងពីបណ្តាតួអង្គពាក់ព័ន្ធដើម្បីធ្វើការរួមគ្នាសម្រាប់គោលដៅរួមក្នុងការឈានផុតពីប្រទេសមានការអភិវឌ្ឍតិចតួច(LDC)។ ក្របខ័ណ្ឌ នៃការត្រួតពិនិត្យ និងការវាយតម្លៃកំពុងត្រូវបានរៀបចំឡើងដោយអគ្គនាយកដ្ឋាន **វ.ប.ន.** នៃក្រសួង **ឧ.វ.ប.ន.** ដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្តផែនទីបង្ហាញផ្លូវនេះ។




ប្រភព៖ S. Kuhlmann and E. Arnold, 2001, RCN in the Norwegian Research and Innovation System, Background Report No. 12 in the Evaluation of the Research Council of Norway. Oslo: Royal Norwegian Ministry of Education, Research and Church Affairs.

រូបភាពទី ១.១៖ ក្របខ័ណ្ឌប្រព័ន្ធនវានុវត្តន៍ជាតិ (Kuhlmann និង Arnold, ២០០១)




រូបភាពទី ១.២៖ សេចក្តីសង្ខេបនៃផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០(MISTI, ២០២១)

ការប្តេជ្ញាចិត្តដ៏មោះមុតរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំរចនាសម្ព័ន្ធក្នុងវិស័យ **វ.ប.ន.** បានឆ្លុះបញ្ចាំងជាសកម្មភាពយ៉ាងច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ជាក់ស្តែង ការសម្រេចចិត្តរបស់រាជរដ្ឋាភិបាលក្នុងការបង្កើតក្រសួង **ឧ.វ.ប.ន.** អំឡុងពេលរាតត្បាតនៃជំងឺកូវីត១៩គឺជាការប្តេជ្ញាចិត្តដែលមិនអាចប្រកែកបានសម្រាប់វិស័យ **វ.ប.ន.**។ លើសពីនេះ លិខិតូបករណ៍ផ្សេងៗក៏ត្រូវបានអនុម័តក្នុងឆ្នាំ២០២១ ផងដែរ។ ដោយសហការជាមួយស្ថាប័នជាតិពាក់ព័ន្ធផ្សេងទៀត ក្រសួង **ឧ.វ.ប.ន.** កំពុងរៀបចំរបៀបវារៈស្រាវជ្រាវជាតិដើម្បីកំណត់អាទិភាពលើប្រធានបទស្រាវជ្រាវក្នុងវិស័យទាំងឡាយរបស់ជាតិ និងការអនុវត្តគម្រោងហ្គោស្ពីន (GO-SPIN) សម្រាប់ការធ្វើសារពើភ័ណ្ឌលើប្រព័ន្ធ **វ.ប.ន.** ដំបូងបង្អស់នៅក្នុងប្រទេស។ ឯកសារទាំងពីរនេះនឹងក្លាយជាឧបករណ៍គោលនយោបាយច្បាស់លាស់មួយទៀតដើម្បីគាំទ្រដល់ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តសកម្មភាពលើវិស័យ **វ.ប.ន.** ឱ្យបានត្រឹមត្រូវ។ ឧបករណ៍ដ៏សំខាន់បំផុតថ្មីមួយទៀតគឺ ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ (RGC, ២០២១)។ គោលនយោបាយនេះមានគោលបំណងទាញយកសក្តានុពលនៃបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង និងបច្ចេកវិទ្យាឌីជីថលសម្រាប់ការបង្កើនផលិតកម្ម ប្រសិទ្ធភាពសេដ្ឋកិច្ច និងសង្គម។ ប្រព័ន្ធអេកូឡូស៊ីដែលមានការអភិវឌ្ឍយ៉ាងលឿនក្នុងពេលថ្មីៗនេះជាសញ្ញាវិជ្ជមាននៃការវិវឌ្ឍវិស័យ **វ.ប.ន.**។ ទោះបីជាមានភាពអំណោយផលបែបនេះក៏ដោយ បញ្ហាប្រឈមជាច្រើនក៏កំពុងជួបប្រទះអំឡុងពេលនៃការអភិវឌ្ឍនេះ។ បញ្ហាប្រឈមទាំងនោះរួមបញ្ចូលកង្វះខាតលើការវិនិយោគជាក់លាក់ក្នុងការស្រាវជ្រាវ និងអភិវឌ្ឍន៍ ការពង្រឹងនូវការអនុវត្តក្របខ័ណ្ឌច្បាប់ ការលើកកម្ពស់ការអប់រំស្វែម និងប្រព័ន្ធគំរូត្រីវ័ណ្ឌ (Triple Helix)។ ព័ត៌មានលម្អិតបន្ថែមអំពីភាពខ្លាំង និងភាពខ្សោយរបស់ប្រព័ន្ធនវានុវត្តន៍ជាតិនៃប្រទេសកម្ពុជាមានភ្ជាប់ក្នុងរូបភាពទី ១.៣។

បញ្ហាប្រឈមទាំងនេះ ត្រូវបានដោះស្រាយ តាមរយៈការខិតខំប្រឹងប្រែងរួមគ្នា ក្នុងចំណោមតួអង្គពាក់ព័ន្ធនឹងវិស័យ **វ.ប.ន.**។ បើតាមទ្រឹស្តី ឧបករណ៍សំខាន់ៗត្រូវបានបង្កើតឡើងដើម្បីគាំទ្រដំណើរការនៃប្រព័ន្ធនវានុវត្តន៍ជាតិ។ ឧបករណ៍ទាំងនោះអាចជាគោលនយោបាយដែលពាក់ព័ន្ធកម្មវិធីលទ្ធកម្ម បទប្បញ្ញត្តិ ប្រព័ន្ធច្បាប់ និងប្រព័ន្ធគ្រប់គ្រង។ ជាទូទៅ ប្រព័ន្ធពាណិជ្ជកម្ម និងកិច្ចសហការ គឺជាគន្លឹះមូលដ្ឋានដើម្បីកំណត់ភាពជោគជ័យនៃនវានុវត្តន៍ជាតិ បន្ថែមពីលើកត្តាគ្រឹះស្ថានឧត្តមសិក្សាល្អៗ ប្រព័ន្ធកម្មសិទ្ធិបញ្ញា ដ៏រឹងមាំ និងការវិនិយោគដ៏ត្រឹមត្រូវទៅលើការស្រាវជ្រាវ និងអភិវឌ្ឍន៍។ តារាងទី១ បង្ហាញនូវធាតុសំខាន់ៗសម្រាប់គាំទ្រប្រព័ន្ធនវានុវត្តន៍ជាតិ។ ទោះជាយ៉ាងណាក៏ដោយ សហគមន៍នវានុវត្តន៍ឈានមុខមួយចំនួនដូចជា «ចិនតៃវ៉ាន់» ឬ «កូរ៉េខាងត្បូង» ត្រូវបានគេសង្កេតនិងកំពុងស្ថិតក្រោមការសិក្សាស្រាវជ្រាវដោយទ្រឹស្តីវិទូផ្នែកនវានុវត្តន៍ដើម្បីបញ្ជាក់ថាធាតុសំខាន់ៗក្នុងតារាងទី១ មានភាពពាក់ព័ន្ធទៅនឹងការឈានមុខរបស់ប្រព័ន្ធនវានុវត្តន៍ជាតិ (Taylor, ២០១៦)។

តារាងទី១៖ ធាតុសំខាន់ៗដែលមានឥទ្ធិពលលើប្រព័ន្ធនវានុវត្តន៍ជាតិ (Taylor, ២០១៦)

| | | | |
|---|---|---|---|
| ហិរញ្ញវត្ថុ | គោលនយោបាយប្រឆាំងការប្រកួតប្រជែងមិនស្មោះត្រង់ | កម្មវិធីលទ្ធកម្មរបស់រដ្ឋាភិបាល | គោលនយោបាយវិទ្យាសាស្ត្រ |
| គោលនយោបាយការពារជាតិ | ទំនាក់ទំនងឧស្សាហកម្ម | បទប្បញ្ញត្តិបរិស្ថាន | គោលនយោបាយការងារ |
| គោលនយោបាយអវកាស | គោលនយោបាយអាហារ | នីតិវិធីចវិកាបេស់រដ្ឋាភិបាល | គោលនយោបាយថាមពល |
| របបអត្រាប្តូរប្រាក់ | ប្រព័ន្ធច្បាប់ | គោលនយោបាយសុខភាព | ការគ្រប់គ្រងដី |
| ច្បាប់កំណត់តំបន់ | គោលនយោបាយទូរគមនាគមន៍ | គោលនយោបាយដឹកជញ្ជូន | គោលនយោបាយផ្ទេរបច្ចេកវិទ្យា |
| សម្បទានកសិកម្ម | គោលនយោបាយពន្ធដារ | បទប្បញ្ញត្តិសុវត្ថិភាព | គោលនយោបាយអន្តោប្រវេសន៍ |




រូបភាពទី១.៣៖ ប្រព័ន្ធនវានុវត្តន៍ជាតិកម្ពុជា ក) ភាពខ្លាំង, ខ) ភាពខ្សោយ (MISTI & UNESCAP, ២០២១)

### ១.២. គោលបំណង

គោលបំណងរួមនៃរបាយការណ៍ **វ.ប.ន.** ឆ្នាំ២០២១ នេះគឺដើម្បីផ្តល់នូវព័ត៌មានចុងក្រោយបំផុតស្តីពីការអភិវឌ្ឍនៃវិស័យ **វ.ប.ន.** ត្រឹមឆ្នាំ ២០២១។ គោលបំណងចម្បងជាក់លាក់គឺដើម្បី ១) រាយការណ៍ពីការអភិវឌ្ឍថ្មីនៃវិស័យ **វ.ប.ន.** នៅចន្លោះឆ្នាំ ២០២០ និង ២០២១, ២) ផ្តល់នូវព័ត៌មាននិងទិន្នន័យថ្មីៗរបស់ស្ថាប័នពាក់ព័ន្ធ ជាពិសេសលើការផ្គត់ផ្គង់ធនធានមនុស្សផ្នែកស្ទែម, និង ៣) បង្ហាញពីស្ថានភាពនៃការវិនិយោគលើវិស័យ **វ.ប.ន.** ដោយក្រសួង-ស្ថាប័ន។ គោលបំណងចុងក្រោយគឺផ្តល់នូវការយល់ឃើញខ្លះៗអំពីស្ថានភាពអភិវឌ្ឍន៍នៃវិស័យ **វ.ប.ន.** ដោយឆ្លុះបញ្ចាំងថាតើចក្ខុវិស័យឆ្នាំ២០៣០ និង២០៥០ របស់រាជរដ្ឋាភិបាលអាចសម្រេចទៅបានតាមរយៈការខិតខំប្រឹងប្រែងពីស្ថាប័នពាក់ព័ន្ធដែរឬទេ។

### ១.៣. វិធីសាស្រ្ត និងវិសាលភាព

ការវិភាគនៅក្នុងរបាយការណ៍នេះត្រូវបានធ្វើឡើងដោយផ្អែកលើទិសដៅដែលបានកំណត់ដោយគោលនយោបាយជាតិស្តីពី **វ.ប.ន.** ឆ្នាំ ២០២០-២០៣០។ សូចនាករដែលបានចែងក្នុងផែនទីបង្ហាញផ្លូវ **វ.ប.ន.** កម្ពុជា ២០៣០ ត្រូវបានប្រើប្រាស់ជាមូលដ្ឋាននៃការវាយតម្លៃ។ ទិន្នន័យ និងព័ត៌មានដែលផ្តល់ដោយស្ថាប័នដែលជាសមាជិកនៃ **ក.ជ.វ.ប.ន.** ក្នុងឆ្នាំ ២០២១ ត្រូវបានប្រើសម្រាប់ការវិភាគ និងការផ្តល់ជាអនុសាសន៍។ ការចង្អុលបង្ហាញពីផ្លូវឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យប្រែក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ ត្រូវបានរៀបរាប់នៅផ្នែកចុងក្រោយនៃរបាយការណ៍នេះផងដែរ។

## ២. តម្រូវការវិស័យ វ.ប.ន. ក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ច

ចាប់ពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១៩ រចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានមានការផ្លាស់ប្តូរជាបន្តបន្ទាប់ (O'Neill, ២០២១)។ អត្រាកំណើននៃវិស័យកសិកម្មបានធ្លាក់ចុះ ហើយអត្រាកំណើននៃឧស្សាហកម្ម និងសេវាកម្មបានស្ទុះងើបឡើងវិញ។ ការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច និងលំនាំកំណើននេះមិនត្រឹមតែប៉ះពាល់ដល់សេដ្ឋកិច្ចប៉ុណ្ណោះទេ ថែមទាំងប៉ះពាល់ដល់ទីផ្សារការងារទៀតផង។ យោងទិន្នន័យចុងក្រោយបានបង្ហាញថា រចនាសម្ព័ន្ធសេដ្ឋកិច្ចនៃវិស័យសំខាន់ៗ បានកើនឡើង ដូចជា សេវាកម្ម ៤១,៦០% ឧស្សាហកម្ម ៣៦,៤០% និង កសិកម្ម ២២,០០% នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០១៩ (UNCTAD, ២០២១)។ រចនាសម្ព័ន្ធសេដ្ឋកិច្ចនេះក៏បង្ហាញយ៉ាងច្បាស់ថាការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ វិស័យឧស្សាហកម្ម និងសេវាកម្មកំពុងរីកចម្រើននៅក្នុងប្រទេស។ ម្យ៉ាងវិញទៀត ចំនួនប្រជាជនវ័យក្មេងនិងសក្តានុពលអាចជាធនធាន ឬបន្ទុកសម្រាប់ប្រទេស។ ការជំរុញឱ្យមានការអភិវឌ្ឍគឺអាស្រ័យលើឱកាសទទួលបានការអប់រំល្អ និងកសាងសមត្ថភាពរបស់យុវជនទាំងនេះតាមរយៈការចូលរួមជាផ្នែកមួយនៃកម្លាំងពលកម្មដែលមានជំនាញរបស់ជាតិ (World Population Review, ២០២១)។ ជាធម្មតា ការងារនៅក្នុងវិស័យនីមួយៗប្រែប្រួល

ពីមួយឆ្នាំទៅមួយឆ្នាំ។ ដូចមានបង្ហាញក្នុងរូបភាពទី ២.១. ការងារលើវិស័យកសិកម្មគឺមានទំហំធំជាងគេ បន្ទាប់មកគឺវិស័យសេវាកម្ម និងឧស្សាហកម្មក្នុងចន្លោះឆ្នាំ ២០០៩ - ២០១៧។ គួរកត់សម្គាល់ផងដែរថា ការងារក្នុងវិស័យសេវាកម្មបានកើនឡើងច្រើនជាងគេនៅក្នុងចន្លោះឆ្នាំ ២០១៨ - ២០១៩។ ទោះជាយ៉ាងណាក៏ដោយ ការងារនៅក្នុងវិស័យសេវាកម្ម និងឧស្សាហកម្មបានកើនឡើង ខណៈពេលដែលការងារក្នុងវិស័យកសិកម្មបានបង្ហាញពីទំនោរធ្លាក់ចុះ ក្នុងចន្លោះឆ្នាំ ២០០៩ - ២០១៩។ ដូច្នេះ កម្លាំងពលកម្មដែលបម្រើក្នុងបរិវត្តកម្មឧស្សាហកម្ម និងសេវាកម្មគួរតែត្រូវបានយកមកពិចារណានិងយកចិត្តទុកដាក់ខ្ពស់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច។ កម្រិតអប់រំ និងស្ថានភាពសុខភាពរបស់កម្លាំងពលកម្មនៃប្រទេសមួយត្រូវបានចាត់ទុកជាសូចនាករក្នុងការវាស់វែងនៅក្នុងបរិបទសេដ្ឋកិច្ច។ ស្ថិតិកម្លាំងពលកម្មតាមភេទក្នុងឆ្នាំ ២០២០ បានបង្ហាញថា ៥១% ជាបុរស និង៤៩% ជាស្ត្រីបានបម្រើការងារក្នុងគ្រប់វិស័យរបស់ប្រទេសកម្ពុជា (UNCTAD, ២០២១)។

ទាក់ទងនឹងការធ្វើពាណិជ្ជកម្មជាមួយបរទេស ទំហំពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាមានទំនោរកើនឡើងពីឆ្នាំ ២០០៥ ដល់ឆ្នាំ ២០២០ (UNCTAD, ២០២១)។ ការនាំចេញត្រូវបានគេប៉ាន់ប្រមាណថាមានតម្លៃទ្វេដងនៅក្នុងឆ្នាំ ២០២០ បើធៀបទៅនឹងឆ្នាំ ២០១៥។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែកំណើននៃការនាំចូលជាបន្តបន្ទាប់ ពាណិជ្ជកម្មមិនមានភាពសមតុល្យ ហើយគម្លាតរវាងការនាំចេញនិងការនាំចូលបានកើនឡើងយ៉ាងឆាប់រហ័សចាប់តាំងពីឆ្នាំ ២០១៥។ បើប្រៀបធៀបទៅនឹងឆ្នាំ ២០១៥ សមតុល្យពាណិជ្ជកម្មត្រូវបានគេរំពឹងទុកថាថយចុះ ៥០% នៅក្នុងឆ្នាំ ២០២១ ដែលជាសញ្ញាល្អ ដោយហេតុថាចំនួននៃការនាំចូលទាបជាងការនាំចេញ។ ទំនិញនាំចេញសំខាន់ៗក្នុងឆ្នាំ ២០២០ គឺភាគច្រើនជាសំលៀកបំពាក់មានតម្លៃប្រមាណ ៥,២ ពាន់លានដុល្លារ គ្រឿងអលង្ការមានតម្លៃប្រមាណ ៣ ពាន់លានដុល្លារ ស្បែកជើងមានតម្លៃ ១,១ ពាន់លានដុល្លារ និងផលិតផលស្បែកមានតម្លៃ ១ ពាន់លានដុល្លារ ដែលភាគច្រើនគឺនាំចេញទៅសហរដ្ឋអាមេរិក (HKTDC, ២០២១)។ ក្រៅពីនេះ ទំនិញនាំចូលសំខាន់ៗរួមមាន ឥន្ធនៈនិងរ៉ែមានតម្លៃ ១,៩ ពាន់លានដុល្លារ យានជំនិះ ១,៧ ពាន់លានដុល្លារ គ្រឿងចក្រ និងគ្រឿងយន្តមានតម្លៃ ១,២ ពាន់លានដុល្លារ និងឧបករណ៍អគ្គិសនីមានតម្លៃ ១,២ ពាន់លានដុល្លារ ដែលភាគច្រើននាំចូលពីប្រទេសចិន។ លើសពីនេះទៀត របាយការណ៍ស្ថិតិ (UNCTAD, ២០២១) ពណ៌នាអំពីរចនាសម្ព័ន្ធនៃការនាំចេញរបស់ប្រទេសអាស៊ាន និងប្រទេសដ៏ទៃទៀតដែលពឹងផ្អែកលើទំនិញផលិតក្នុងវិស័យកម្មន្តសាលក្នុងឆ្នាំ ២០២០។ ទាំងនេះគឺជាឧទាហរណ៍នៃប្រទេសដែលនាំចេញទំនិញផលិតក្នុងវិស័យកម្មន្តសាលរួមមានប្រទេសចិន ៩៤% កម្ពុជា ៨៧% វៀតណាម ៨៦% សិង្ហបុរី ៧៨% ម៉ាឡេស៊ី ៧៣% និងប្រទេសថៃ ៧២%។




រូបភាពទី ២.១៖ របាយការងារបែងចែកទៅតាមវិស័យនានា (ប្រភព៖ World Bank, ២០២១)

ថ្វីត្បិតតែរក្សាបានស្ថេរភាពកំណើនប្រមាណ ៧% មុនពេលរាតត្បាតនៃជំងឺកូវីដ១៩ក៏ដោយ សេដ្ឋកិច្ចកម្ពុជាបានជួបប្រទះនឹងការធ្លាក់ចុះដែលមិនធ្លាប់មានពីមុនមក ដោយមានអត្រាអតិផរណាប្រមាណ -៤% ពេញមួយឆ្នាំ ២០២០ (Asian Development Bank, ២០២០)។ វិស័យដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយជំងឺរាតត្បាតគឺវិស័យទេសចរណ៍ ខណៈដែលអ្នកជំនាញបានអះអាងថាស្ថានភាពនេះអាចនឹងត្រូវអូសបន្លាយពីរទៅបីឆ្នាំដើម្បីវិលទៅរកស្ថានភាពដើមឡើងវិញ (Asian Development Bank, ២០២០)។ រាជរដ្ឋាភិបាលបានកំណត់ថាសេដ្ឋកិច្ចកម្ពុជាត្រូវតែបន្តរីកចម្រើន ដោយមិនអាចពឹងផ្អែកលើចលករបែបប្រពៃណីបានទៀតទេ។ រាជរដ្ឋាភិបាលបានមើលឃើញពីឱកាសរីកចម្រើនថ្មីមួយទៀតតាមរយៈការបន្សាំខ្លួន និងចាប់យកបដិវត្តន៍ឧស្សាហកម្ម ៤.០ ក្នុងគោលបំណងជំរុញសេដ្ឋកិច្ចឌីជីថល ដូចដែលបានបង្ហាញពីការបន្សាំខ្លួន និងការចាប់យកបដិវត្តន៍ឧស្សាហកម្ម ៤.០ នៅកម្ពុជាតាមរយៈការធ្វើឱ្យប្រសើរឡើងនូវខ្សែច្រវាក់តម្លៃឧស្សាហកម្ម ការធ្វើពិពិធកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ច និងការបង្កើនសមត្ថភាពនវានុវត្តន៍ (UNDP, ២០២០)។

ជាសង្ខេប វិស័យ **វ.ប.ន.** នឹងត្រូវតែដើរតួនាទីចាំបាច់សម្រាប់កម្ពុជាក្នុងការសម្រេចបាននូវចក្ខុវិស័យប្រកបដោយមហិច្ឆតាជាប្រទេសដែលមានចំណូលខ្ពស់ និងយកនវានុវត្តន៍ជាមូលដ្ឋានជំរុញនៅឆ្នាំ ២០៥០។ **វ.ប.ន.** គឺជាកម្លាំងចលករសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច បង្កើនលទ្ធភាពទទួលបានទីផ្សារការងារ ពង្រឹងខ្សែច្រវាក់ផ្គត់ផ្គង់ភ័ស្តុភារ និងបើកទីផ្សារថ្មីសម្រាប់សហគ្រាស។ ប្រទេសកម្ពុជាបានបង្កើតយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ដើម្បីបង្កើនតម្លៃបន្ថែម និងការប្រកួតប្រជែងក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម រួមទាំងផលិតផលសម្លៀកបំពាក់ អង្ករ និងទេសចរណ៍។ យុទ្ធសាស្ត្រនេះមានគោលបំណងលើកកម្ពស់ជំនាញរបស់កម្មកររោងចក្រ ជំរុញការវិនិយោគក្នុងនិងក្រៅស្រុកដែលមានតម្លៃបន្ថែមខ្ពស់ និងពិពិធកម្មទីផ្សារនាំចេញ។

## ៣. ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ

ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់នៃជំងឺកូវីដ១៩ និងដើម្បីដើរលើវិថីឆ្ពោះទៅរកចក្ខុវិស័យរបស់ប្រទេសក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម រាជរដ្ឋាភិបាលកម្ពុជាបានបង្កើត និងកំណត់គោលដៅនិងយុទ្ធសាស្ត្រច្បាស់លាស់សម្រាប់ការអនុវត្តគោលនយោបាយទាំងនេះ។ ឧទាហរណ៍ **ក.ជ.វ.ប.ន.** បានអនុម័តលើឯកសារគោលនយោបាយចំនួនពីរគឺ ប្រព័ន្ធអេកូឡូស៊ី **វ.ប.ន.** កម្ពុជា និងផែនទីបង្ហាញផ្លូវ **វ.ប.ន.** កម្ពុជា ២០៣០។ គោលបំណងរបស់ឯកសារទី១ គឺផ្តល់នូវជាតុចូលដែលជាមូលដ្ឋានផ្អែកលើភស្តុតាងសម្រាប់ការបង្កើតផែនទីបង្ហាញ **វ.ប.ន.** កម្ពុជា ឬគោលនយោបាយ **វ.ប.ន.** ដទៃទៀត ខណៈឯកសារគោលនយោបាយទី២ មានគោលបំណងបង្ហាញទិសដៅការអភិវឌ្ឍ **វ.ប.ន.** និងការអនុវត្តសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយបរិយាបន្ន (MISTI, ២០២១)។ វឌ្ឍនភាពថ្មីៗលើក្របខ័ណ្ឌច្បាប់ និងគោលនយោបាយទាក់ទងនឹង **វ.ប.ន.** ត្រូវបានពិពណ៌នាដូចខាងក្រោម។

### របៀបវារៈស្រាវជ្រាវជាតិ

ដោយមានជំនួយបច្ចេកទេសពីគណៈកម្មការសេដ្ឋកិច្ច និងសង្គម របស់អង្គការសហប្រជាជាតិ ប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក(UNESCAP) ក្រសួង **ឧ.វ.ប.ន.** កំពុងកសាងនូវរបៀបវារៈស្រាវជ្រាវជាតិដើម្បីគាំទ្រដល់ការអនុវត្តផែនទីបង្ហាញផ្លូវ **វ.ប.ន.**កម្ពុជា ២០៣០ (MISTI & UNESCAP, ២០២១)។ របៀបវារៈស្រាវជ្រាវជាតិមានគោលបំណងកំណត់នូវមូលដ្ឋានច្បាស់លាស់លើវិស័យសក្តានុពលដែលត្រូវស្រាវជ្រាវ គោលនយោបាយ និងយន្តការផ្តល់មូលនិធិ និងភាគីពាក់ព័ន្ធកំពុងត្រូវបានបង្កើតឡើង។ របៀបវារៈស្រាវជ្រាវជាតិនឹងជួយកំណត់ភាគីពាក់ព័ន្ធសំខាន់ៗនៅក្នុងប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវកម្ពុជាតាមរយៈការជំរុញការស្រាវជ្រាវលើផ្នែកដែលមានសក្តានុពលនៅក្នុងវិស័យ **វ.ប.ន.** ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយបរិយាបន្ន និងតាមរយៈការបង្ហាញពីប្រព័ន្ធអេកូឡូស៊ីនៃមូលនិធិស្រាវជ្រាវ។ របៀបវារៈស្រាវជ្រាវជាតិ ត្រូវបានគេរំពឹងថានឹងត្រូវបានបញ្ចប់ និងដាក់ឱ្យដំណើរការនៅឆ្នាំ ២០២២។

### ការសង្កេតសកលនៃលិខិតុករណ៍គោលនយោបាយ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ហ្គោស្ទីន)

ដោយមានការគាំទ្រពីអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ (យូណេស្កូ) ក្រសួង **ឧ.វ.ប.ន.** កំពុងធ្វើការសិក្សាលើហ្គោស្ទីន សម្រាប់ប្រទេសកម្ពុជា ដែលនឹងផ្តល់ជូន អ្នកធ្វើសេចក្តីសម្រេចចិត្ត សមាជិកសភា គ្រឹះស្ថានឧត្តមសិក្សា វិស័យឯកជន អ្នកឯកទេស និងសាធារណៈជនទូទៅ នូវសំណុំព័ត៌មានចម្រុះជាច្រើនស្តីពីប្រព័ន្ធអេកូឡូស៊ី **វ.ប.ន.** នៅកម្ពុជា។ លទ្ធផលនៃការសិក្សានឹងត្រូវបានប្រើជាឯកសារគោលនយោបាយសំខាន់មួយសម្រាប់ភាគីពាក់ព័ន្ធ **វ.ប.ន.** ក្នុងការបង្កើត និងបណ្តុះប្រព័ន្ធនវានុវត្តន៍ជាតិនៅក្នុងប្រទេសកម្ពុជា។ តាមរយៈវិធីសាស្ត្រចូលរួម និងបរិយាបន្ន ក្រសួង **ឧ.វ.ប.ន.** និងយូណេស្កូ កំពុង

ធ្វើការយ៉ាងជិតស្និទ្ធជាមួយភាគីពាក់ព័ន្ធ វ.ប.ន. ទាំងអស់ ដើម្បីបញ្ចប់ហ្គោស្លីន សម្រាប់ប្រទេសកម្ពុជានៅក្នុងឆ្នាំ ២០២២។

**ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន**

ភាពជាដៃគូរវាងរដ្ឋ និងឯកជនត្រូវបានកំណត់ថាជាធាតុផ្សំដែលមិនអាចជៀសវាងបានសម្រាប់ការអភិវឌ្ឍ។ ដើម្បីលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋ និងឯកជន ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន ត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០២១។ នៅក្នុងមាត្រា១ នៃច្បាប់នេះមានគោលបំណងលើកកម្ពស់ការគ្រប់គ្រងយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ក្នុងការរៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងគម្រោងសេវាសាធារណៈប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព ចីរភាព តម្លាភាព គណនេយ្យភាព និងយុត្តិធម៌ ដើម្បីជាឧត្តមប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម នៅព្រះរាជាណាចក្រកម្ពុជា ដោយៈ ១)កំណត់ស្ថាប័នមានសមត្ថកិច្ចសម្រាប់គ្រប់គ្រងនិងអនុវត្តគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន ជាលក្ខណៈប្រព័ន្ធ, ២)បង្កើតក្របខ័ណ្ឌដើម្បីអភិវឌ្ឍ អនុវត្ត គ្រប់គ្រង និងតាមដានត្រួតពិនិត្យគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន, ៣)បង្កើតវិធាន វិធីសាស្ត្រ នីតិវិធី និងរចនាសម្ព័ន្ធសម្រាប់គ្រប់គ្រងនិងអនុវត្តកិច្ចលទ្ធកម្ម ក្នុងក្របខ័ណ្ឌគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន កំណត់យន្តការគាំទ្រផ្នែកហិរញ្ញវត្ថុ និងការលើកទឹកចិត្តវិនិយោគសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន។ នៅក្នុងមាត្រា២ ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះការគ្រប់គ្រងលើការអភិវឌ្ឍនិងការអនុវត្តគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងវិស័យមានលក្ខណសម្បត្តិគ្រប់គ្រាន់ស្របតាមមាត្រា៨នៃច្បាប់នេះ ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សាធារណៈ និង/ឬផ្តល់សេវាសាធារណៈ។

**ច្បាប់វិនិយោគថ្មី**

ច្បាប់វិនិយោគថ្មីត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ ២០២១។ ច្បាប់នេះមានគោលបំណងបង្កើតនូវ «ក្របខ័ណ្ឌគតិយុត្តដែលបើកចំហ មានតម្លាភាព អាចប៉ាន់ប្រមាណទុកជាមុនបានប្រកបដោយភាពអំណោយផលសម្រាប់ការវិនិយោគ ដើម្បីទាក់ទាញនិងលើកកម្ពស់ ការវិនិយោគដោយបុគ្គលសញ្ជាតិខ្មែរ ឬបរទេសប្រកបដោយគុណភាព ប្រសិទ្ធភាព និងប្រសិទ្ធផល សំដៅ អភិវឌ្ឍសេដ្ឋកិច្ច-សង្គម នៅក្នុងព្រះរាជាណាចក្រកម្ពុជា» ។ ច្បាប់នេះ ផ្តល់ការធានា និងការលើកទឹកចិត្តដល់គម្រោងវិនិយោគដែលមានលក្ខណៈដូចខាងក្រោមៈ ១)រួមចំណែកដល់ការបណ្តុះបណ្តាលជំនាញ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងនវានុវត្តន៍, ២)បណ្តុះឱ្យមានការលូតលាស់នៃសហគ្រាសធុនតូច និងមធ្យម និងផ្តល់ការគាំទ្រដល់សហគ្រាសធុនតូច និងមធ្យមតាមរយៈការបណ្តុះបណ្តាលជំនាញ ការលើកទឹកចិត្តបុគ្គលិក និងការវិនិយោគលើគ្រឿងម៉ាស៊ីន ឬឧបករណ៍ផលិតកម្ម, ៣) ការបង្កើតសួនឧស្សាហកម្ម សួនវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងមជ្ឈមណ្ឌលពាណិជ្ជកម្ម, ៤) ការលើកកម្ពស់ការចូលរួមយ៉ាងសកម្មពីវិស័យឯកជនក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ៥) ការលើកកម្ពស់

វិស័យភ័ស្តុភារ និងឧស្សាហកម្មឌីជីថល, និង ៦) ការរួមចំណែកដល់ការគ្រប់គ្រង និងការការពារ បរិស្ថាន និងការអភិរក្សជីវៈចម្រុះ (DFDL, ២០២១)។

ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស វាមានសារៈសំខាន់ណាស់ក្នុងការណែនាំឱ្យបានឆាប់រហ័សនូវបទប្បញ្ញត្តិចាំបាច់ និងការរៀបចំដើម្បីអនុវត្តច្បាប់វិនិយោគថ្មីដែលទើបបានដាក់ឱ្យប្រើ ដោយពិចារណាលើលក្ខខណ្ឌតម្រូវពីខាងក្រៅ។ តួយ៉ាង អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ថ្មីនេះ រួមទាំងបទប្បញ្ញត្តិ និងការរៀបចំចាំបាច់មួយចំនួន ដូចជានីតិវិធីចុះឈ្មោះ និងស្នើសុំគម្រោងវិនិយោគ និងនីតិវិធីពិសេសសម្រាប់លិខិតអនុញ្ញាតការងារ និងការស្នើសុំការងារ នឹងត្រូវបានរៀបចំនិងដាក់ឱ្យដំណើរការ។ លើសពីនេះ ច្បាប់វិនិយោគថ្មីក៏អាចជួយលើកកម្ពស់ផលិតភាពការងារ និងប្រព័ន្ធលើកទឹកចិត្តដែលផ្តល់នូវការបណ្តុះបណ្តាលជំនាញ កន្លែងស្នាក់នៅ កន្លែងបណ្តុះបណ្តាលក្មេង កន្លែងថែទាំសុខភាព និងសេវាដឹកជញ្ជូន ដល់កម្លាំងពលកម្ម។ ការលើកទឹកចិត្តតាមរយៈការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងនវានុវត្តន៍ និងទំនើបកម្មគ្រឿងយន្ត នឹងបង្កឱ្យមានការចាប់យក និងការផ្ទេរបច្ចេកវិទ្យាថ្មីៗ។

ជាងនេះទៅទៀត ច្បាប់វិនិយោគថ្មីក៏អាចផ្តល់ឱកាសដល់ការវិនិយោគមួយចំនួនដែលមានសក្តានុពលខ្ពស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ការផ្តល់ការលើកលែងពន្ធលើតម្លៃបន្ថែមដល់ការទិញផលិតផលក្នុងស្រុកសម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អាចជំរុញឱ្យមានទំនាក់ទំនងរវាងវិស័យនាំចេញកម្មន្តសាលដែលវិនិយោគផ្ទាល់ពីបរទេសជាមួយវិស័យសហគ្រាសធុនតូច និងមធ្យមក្នុងស្រុក។ លើសពីនេះ ការផ្សព្វផ្សាយច្បាប់ថ្មី ក៏ដូចជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ តំបន់ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ ដែលបានចុះហត្ថលេខានាពេលថ្មីៗនេះ គឺជាការចាំបាច់ដែលត្រូវធ្វើឡើងដើម្បីបង្កើនការយល់ដឹងអំពីច្បាប់ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មទាំងនោះ ដល់វិនិយោគិនទាំងឡាយ (World Bank, ២០២១)។

## ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥

នៅខែមិថុនា ឆ្នាំ ២០២១ ក្នុងគោលបំណងបង្កើនល្បឿនកំណើនសេដ្ឋកិច្ចក្រោយជំងឺរាតត្បាតជាសកល និងប្រកបដោយបរិយាបន្ន រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ដែលមានចក្ខុវិស័យវែងឆ្ងាយក្នុងការតម្រង់ទិសការអភិវឌ្ឍ និងដំណើរការនៃបរិវត្តកម្មឌីជីថល និងមានវិធីសាស្ត្រជាជំហានៗដែលបានកំណត់យ៉ាងជាក់លាក់ដោយផ្តោតលើតម្រូវការ ធនធាន និងសមត្ថភាពរបស់វិស័យរដ្ឋនិង ឯកជន។ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នូវយន្តការជាក់លាក់ចំនួនបី ៖ ១)ការគាំទ្រ និង ការលើកកម្ពស់ប្រព័ន្ធអេកូឡូស៊ីអំណោយផល ដល់នវានុវត្តន៍ និង ការវិនិយោគ, ២)ការបង្កើនភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល, និង ៣) ការជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ទំនាក់ទំនង បច្ចេកវិទ្យា បណ្តាញ ឬទិន្នន័យ និងទំនាក់ទំនងរូបវន្ត។ ក្របខ័ណ្ឌគោលនយោបាយនេះផ្តោតលើសមាសធាតុចំនួនប្រាំដែលបែកចេញជាគ្រឹះចំនួនពីររួមមាន៖ ១) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល និង ២) ការកសាងទំនុកចិត្ត និងភាពជឿជាក់លើប្រព័ន្ធឌីជីថល និងសសរស្តម្ភចំនួនបីរួមមាន៖១) ការកសាងពលរដ្ឋឌីជីថល រួមទាំងភាពជាអ្នក

ដឹកនាំឌីជីថល ធនធានមនុស្សដែលមានទេពកោសល្យឌីជីថល, ២) ការកសាងរដ្ឋាភិបាលឌីជីថល រួមទាំងសេវាសាធារណៈ ការកែលម្អការអនុវត្តឌីជីថល និងអភិបាលកិច្ចផ្អែកលើទិន្នន័យ, និង ៣) ការជំរុញធុរកិច្ចឌីជីថល រួមមានដូចជា បរិវត្តកម្មឌីជីថលសម្រាប់សហគ្រាស ភាពជាសហគ្រិន ប្រព័ន្ធអេកូឡូស៊ីសម្រាប់ធុរកិច្ចថ្មី និងខ្សែច្រវាក់តម្លៃឌីជីថល (RGC, ២០២១)។ រាជរដ្ឋាភិបាលក៏បានបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមឌីជីថល ដើម្បីកសាងមូលដ្ឋានគ្រឹះនៃសង្គមឌីជីថល ដើម្បីជំរុញកំណើនសេដ្ឋកិច្ចថ្មី នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ ២០២១។ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមឌីជីថល ត្រូវបានកំណត់ជាសេនាធិការរបស់រាជរដ្ឋាភិបាលដើម្បីរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និងបរិវត្តកម្មឌីជីថលនៅក្នុងគ្រប់តួអង្គសង្គមរួមទាំងរដ្ឋ ទាំងពលរដ្ឋ និងទាំងធុរជន។ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមឌីជីថលមានតួនាទីដឹកនាំសម្របសម្រួល និងជំរុញការកសាង និងការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីសង្គមឌីជីថលរស់រវើកដើម្បីជំរុញសន្ទុះកំណើនសេដ្ឋកិច្ចថ្មី និងលើកកម្ពស់សុខុមាលភាពសង្គម។ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមឌីជីថលក៏មានទំនួលខុសត្រូវសំខាន់ៗដែលទាក់ទងនឹងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល ដូចជាការកំណត់ចក្ខុវិស័យ និងគោលការណ៍ ការតម្រង់ទិស ការផ្ដល់ប្រឹក្សា កៀរគរធនធានហិរញ្ញវត្ថុ ធនធានបច្ចេកទេស និងធនធានមនុស្ស និងការលើកកម្ពស់ការអនុវត្តច្បាប់។

## ច្បាប់ផ្ទេរបច្ចេកវិទ្យា

ដោយមើលឃើញពីតម្រូវការផ្នែកច្បាប់ និងនីតិវិធីនៃការផ្ទេរបច្ចេកវិទ្យានៅក្នុងប្រទេសកម្ពុជា អគ្គនាយកដ្ឋាន **វ.ប.ន.** នៃ ក្រសួង **ឧ.វ.ប.ន.** បាននិងកំពុងធ្វើការសិក្សាផ្នែកបច្ចេកទេស និងធ្វើសេចក្តីព្រាងច្បាប់នេះ។ ជារួម ច្បាប់នេះមានគោលបំណងគ្រប់គ្រង និងលើកកម្ពស់សកម្មភាពផ្ទេរបច្ចេកវិទ្យាគ្រប់ប្រភេទក្នុង និងក្រៅប្រទេសកម្ពុជាដូចខាងក្រោម៖ ១)ជំរុញលើកកម្ពស់ការផ្ទេរបច្ចេកវិទ្យាថ្មី និងនវានុវត្តន៍ពីស្ថាប័នមួយ ទៅស្ថាប័នមួយ ឬពីរូបវន្តបុគ្គលទៅនីតិបុគ្គល ដើម្បីធ្វើទំនើបកម្មក្នុងវិស័យឧស្សាហកម្ម និងវិស័យដទៃទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា, ២) ការពារសិទ្ធិ កាតព្វកិច្ច និងផលប្រយោជន៍ របស់ស្ថាប័ន អង្គភាព រូបវន្តបុគ្គល នីតិបុគ្គល ឬប្រតិបត្តិករដែលចូលរួមក្នុងសកម្មភាពផ្ទេរបច្ចេកវិទ្យានៅក្នុងព្រះរាជាណាចក្រកម្ពុជា, ៣) កំណត់វិធានការផ្ទេរបច្ចេកវិទ្យា និងទប់ស្កាត់ការលួចចម្លងបច្ចេកវិទ្យា, ៤)ការគ្រប់គ្រងបច្ចេកវិទ្យា និងការផ្ទេរបច្ចេកវិទ្យា ដែលអំណោយផលដល់សេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន។ សេចក្តីព្រាងនេះត្រូវបានរំពឹងថានឹងត្រូវបញ្ចប់នៅឆ្នាំ ២០២២ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួង ពិនិត្យ សម្រេច និងចាត់ចែងនិតិវិធីបន្ត។

## ច្បាប់ស្តីពីស្តង់ដារ

ច្បាប់ស្តីពីស្តង់ដារកម្ពុជា («ច្បាប់ស្តង់ដារ») ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៧ អនុម័តដោយព្រឹទ្ធសភានៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៧ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០០៧។ ច្បាប់នេះជាលិខិតូបករណ៍គតិយុត្តមួយ ដែលតម្រូវឱ្យកម្ពុជាអនុម័តដោយអនុលោមតាមការចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក(WTO)។ យោងតាមមាត្រា ២

ច្បាប់នេះមានគោលបំណង ៖ ១) ធ្វើឱ្យកាន់តែប្រសើរឡើងនូវគុណភាពផលិតផល សេវាកម្ម និងការគ្រប់គ្រង, ២) បង្កើនប្រសិទ្ធភាពផលិតកម្មឱ្យកាន់តែប្រសើរឡើង និងងាយស្រួល, ៣) ធានាឱ្យការធ្វើពាណិជ្ជកម្ម មានលក្ខណៈត្រឹមត្រូវ និងងាយស្រួល, ៤) បង្កឱ្យការប្រើប្រាស់ផលិតផលមានលក្ខណៈងាយស្រួល, ៥)បង្កើនការការពារអ្នកប្រើប្រាស់ និងលើកកម្ពស់សុខុមាលភាពសាធារណៈ។ ច្បាប់នេះ មានវិសាលភាពលើរាល់សកម្មភាពដែលទាក់ទងនឹងស្តង់ដារូបនីយកម្ម ការធានាគុណភាព និងសកម្មភាពពាក់ព័ន្ធទាំងឡាយដែលមានក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ច្បាប់ស្តីពីមាត្រាសាស្ត្រ

ច្បាប់ស្តីពីមាត្រាសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី១១ ខែសីហា ឆ្នាំ ២០០៩។ ច្បាប់នេះមានគោលបំណង ៖ ១) ធានាឱ្យការធ្វើពាណិជ្ជកម្ម មានភាពយុត្តិធម៌និងត្រឹមត្រូវ, ២)បង្កឱ្យការប្រើប្រាស់ ឧបករណ៍មាត្រាសាស្ត្រ មានភាពត្រឹមត្រូវសុចរិត ធានាផលប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និង អ្នកប្រើប្រាស់ ផលិតផលទំនិញ និងសេវាកម្ម, ៣)ធានាធ្វើឱ្យកាន់តែប្រសើរឡើងនូវគុណភាពទំនិញ ផលិតផល សេវាកម្ម និង គ្រប់គ្រង, ៤)កំណត់អត្តសញ្ញាណ និង លុបបំបាត់របាំងបច្ចេកទេស ដើម្បីឱ្យមានសុខដុមនីយកម្មក្នុងសកម្មភាពពាណិជ្ជកម្ម លើវិស័យនីត្យានុក្កូលមាត្រាសាស្ត្រ, ៥)ធ្វើឱ្យមានជំនឿ និង ទំនុកចិត្តលើការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រក្នុងសកម្មភាពពាណិជ្ជកម្ម និងវិស័យផ្សេងៗទៀត ដើម្បីសុខភាព សុវត្ថិភាព និងបរិស្ថាន, និង ៦) សម្រួលការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស ដើម្បីភាពរីកចម្រើននៃសេដ្ឋកិច្ច។

## ច្បាប់កម្មសិទ្ធិបញ្ញា

កម្ពុជាទទួលបានសមាជិកភាពរបស់ខ្លួននៅក្នុងអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ក្នុងឆ្នាំ ១៩៩៥ និងជាសមាជិកទី ១០ នៃអាស៊ាននៅឆ្នាំ ១៩៩៩ ។ កម្ពុជាបានក្លាយជាសមាជិកនៃ អង្គការពាណិជ្ជកម្មពិភពលោក ក្នុងឆ្នាំ ២០០៤ ដែលនាំទៅដល់ការក្លាយជាប្រទេសហត្ថលេខីក្នុងកិច្ចព្រមព្រៀងផ្នែកពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា សមាជិកភាពទៅក្នុងពិធីសារម៉ាទ្រីដសម្រាប់ការចុះបញ្ជីម៉ាកអន្តរជាតិត្រូវបានផ្តល់ជូនក្នុងឆ្នាំ២០១៥ ខណៈពេលដែលសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (PCT) ត្រូវបានផ្តល់ជូនក្នុងឆ្នាំ២០១៦។ ថ្មីៗនេះ កម្ពុជាបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់លើការផ្តល់ និងទទួលស្គាល់ប្រកាសនីបត្រតត្តកម្ម ជាមួយការិយាល័យកម្មសិទ្ធិបញ្ញានៃប្រទេសសិង្ហបុរី(IPOS) ក្នុងឆ្នាំ ២០១៦ ជាមួយការិយាល័យប្រកាសនីបត្រតត្តកម្មនៃប្រទេសជប៉ុន (JPO) ក្នុងឆ្នាំ ២០១៦ ជាមួយការិយាល័យប្រកាសនីបត្រតត្តកម្មអឺរ៉ុប (EPO) ក្នុងឆ្នាំ ២០១៧ និងជាមួយការិយាល័យកម្មសិទ្ធិបញ្ញារបស់រដ្ឋនៃប្រទេសចិន (SIPO) ក្នុងឆ្នាំ ២០១៨។ លើសពីនេះ កម្ពុជាបានចុះហត្ថលេខាលើច្បាប់ទីក្រុងហ្សឺណែវ នៃកិច្ចព្រមព្រៀងទីក្រុងលីសបោន (Lisbon) ស្តីពីការសម្គាល់ប្រភពដើម និងភូមិសាស្ត្រថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០១៨។ សមាជិកភាពរបស់ប្រទេសកម្ពុជាទៅក្នុងស្ថាប័នអន្តរជាតិទាំងនេះ ជាពិសេសអង្គការពាណិជ្ជកម្មពិភពលោកបាននាំឱ្យមានការបង្កើតច្បាប់ទាក់ទងនឹងច្បាប់កម្មសិទ្ធិបញ្ញាជាច្រើនដូចខាងក្រោម៖ ១) ច្បាប់ស្តីពីការគ្រប់គ្រងគុណភាពសុវត្ថិភាពលើផលិតផល ទំនិញ និងសេវា (២០០០), ២) ច្បាប់ស្តីពីម៉ាក

ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ (២០០២), ៣) ច្បាប់ស្ដីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម(២០០៣), ៤) ច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធប្រហាក់ប្រហែល (២០០៣), ៥) ច្បាប់ស្ដីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ(២០០៨), និង ៦) ច្បាប់ស្ដីពីម៉ាក់សម្គាល់ភូមិសាស្ត្រទំនិញ (២០១៤)។ ច្បាប់ទាំងនេះត្រូវបានបង្កប់ដោយគោលបំណងចំនួន ៤៖

ក. ពង្រឹងលទ្ធភាព និងសមត្ថភាពនៅក្នុងសេដ្ឋកិច្ចកម្ពុជាក្នុងការផ្ដល់ និងប្រើប្រាស់សេវាកម្មកម្មសិទ្ធិបញ្ញា ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា។

ខ. ពង្រឹងលទ្ធភាព និងសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការផ្ដល់នូវគោលនយោបាយ សេវាកម្ម និងការអនុវត្តកម្មសិទ្ធិបញ្ញា ដើម្បីគាំទ្រដល់វិស័យកសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម វប្បធម៌ និងឧស្សាហកម្មទេសចរណ៍របស់កម្ពុជា។

គ. ធ្វើឱ្យប្រសើរឡើងនូវការស្វែងយល់ និងការយល់ដឹងរបស់ប្រជាជនឱ្យកាន់តែទូលំទូលាយអំពីតួនាទីសេដ្ឋកិច្ចនៃកម្មសិទ្ធិបញ្ញាដើម្បីគាំទ្រដល់ការកើនឡើងនៃការប្រើប្រាស់ប្រព័ន្ធកម្មសិទ្ធិបញ្ញាដោយធុរកិច្ចជនកម្ពុជា។

ឃ. អភិវឌ្ឍ និងរក្សាច្បាប់កម្មសិទ្ធិបញ្ញារបស់កម្ពុជា ជាមួយនឹងស្តង់ដារអន្តរជាតិ ដើម្បីបំពេញតម្រូវការសេដ្ឋកិច្ច និងសង្គមរបស់កម្ពុជា។

## ៤. ធនធានមនុស្ស

ប្រទេសជាតិមួយអាចរីកចម្រើនទៅបានលុះត្រាតែមានធនធានមនុស្សដែលមានជំនាញគ្រប់គ្រាន់។ ដើម្បីមានធនធានមនុស្សដែលប្រកបដោយគុណវុឌ្ឍិ គ្រប់គ្នាត្រូវតែឆ្លងកាត់ប្រព័ន្ធអប់រំត្រឹមត្រូវដែលគាំទ្រដោយរាជរដ្ឋាភិបាល។ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងដើម្បីកែលម្អនិងអភិវឌ្ឍប្រព័ន្ធអប់រំរបស់ខ្លួន និងដាក់ចេញគោលនយោបាយជាច្រើនដើម្បីជំរុញវិស័យនេះ។ ដើម្បីពង្រីកមូលធនមនុស្សរបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងតម្រូវការទីផ្សារ កម្ពុជាបានព្យាយាមដាក់ចេញនូវគោលនយោបាយសំខាន់ៗជាច្រើន និងផែនការយុទ្ធសាស្ត្រនានា ជាពិសេសដើម្បីផ្គត់ផ្គង់ទីផ្សារការងារ និងតម្រូវការក្នុងវិស័យនានា។ ដូចច្នេះ ផ្នែកនេះរៀបរាប់ពីវឌ្ឍនភាពនៃការអភិវឌ្ឍធនធានមនុស្សនៅកម្រិតផ្សេងៗគ្នា ទាំងការអប់រំក្នុងប្រព័ន្ធ និងការអប់រំក្រៅប្រព័ន្ធ។

### ៤.១. កម្រិតមធ្យមសិក្សាទុតិយភូមិ

យោងតាមទិន្នន័យដែលទទួលបាននៅប្រាំឆ្នាំចុងក្រោយ (២០១៦-២០២០) ចំនួនសិស្សដែលបានចុះឈ្មោះចូលរៀនមានការកើនឡើងជាប្រចាំឆ្នាំ ជាពិសេសចំនួនសិស្សដែលបានចុះឈ្មោះចូលរៀនថ្នាក់ទី ១១ និង ១២។ ចំនួនសិស្សថ្នាក់ទី១១ បានកើនឡើងជាមធ្យម ៦៨៨៤ នាក់ក្នុងមួយឆ្នាំ។ ដោយឡែក ចំនួនសិស្សស្រីបានកើនឡើងចំនួន ៤៥៧៥ នាក់ (ប្រហែល ៥៣%នៃចំនួនសិស្សសរុប) ជាមធ្យមក្នុងមួយឆ្នាំ (រូបភាពទី ៤.១)។ ស្ថិតិនេះបញ្ជាក់ថាចំនួនសិស្សស្រីមានច្រើនជាងសិស្សប្រុស។ ស្រដៀងគ្នានេះដែរ ចំនួនសិស្សសរុបដែលបានចុះឈ្មោះចូលរៀនថ្នាក់ទី១២ ត្រូវបានគេសង្កេតឃើញថាមានការកើនឡើងពីឆ្នាំ ២០១៦ ដល់ ២០២០ ដែលជាមធ្យមមាន

សិស្សកើនឡើង ៥២៦០នាក់ក្នុងមួយឆ្នាំ (រូបភាព ៤.១)។ ចំនួនសិស្សស្រីជាមធ្យមមាន ៥២% នៃចំនួនសិស្សសរុប។ ម្យ៉ាងវិញទៀតចំនួនសិស្សស្រីបានកើនឡើងជាមធ្យម ៣៧៨៨នាក់ក្នុងមួយឆ្នាំ។




រូបភាពទី ៤.១៖ ចំនួនសិស្សនៅកម្រិតវិទ្យាល័យ

ចំនួនសិស្សគិតជាភាគរយផ្នែកស្ទែមសម្រាប់ថ្នាក់ទី១១ ពីឆ្នាំ២០១៦ ដល់ ២០២០ ត្រូវបានបង្ហាញក្នុងរូបភាពទី ៤.២។ គេសង្កេតឃើញថាភាគច្រើនសិស្សចុះឈ្មោះចូលរៀនមុខវិជ្ជាស្ទែមជាមធ្យម ៦៧.៤% ចន្លោះឆ្នាំ ២០១៦ ដល់ ២០២០។ ទំនោរសិស្សផ្នែកស្ទែមនៅថ្នាក់ទី១១ មានការថយចុះពី ៨២% នៅឆ្នាំ២០១៦ មកត្រឹម ៦២% នៅឆ្នាំ២០២០ ខណៈពេលដែលមានទំនោរផ្ទុយ(កើន)ចំពោះសិស្សផ្នែកមិនមែនស្ទែម (រូបភាពទី ៤.២)។ ចំនួនសិស្សស្រីក្នុងមុខវិជ្ជាស្ទែមក្នុងថ្នាក់ទី១១ មានការកើនឡើងបន្តិចពី ៣៥% ក្នុងឆ្នាំ២០១៦ កើនទៅ ៥៦% ក្នុងឆ្នាំ២០២០ (រូបភាពទី ៤.៣)។ គួរកត់ចំណាំផងដែរថាចំនួនសិស្សសរុបសម្រាប់ថ្នាក់ទី១១ និង១២ ត្រូវបានប្រមូលទិន្នន័យនៅរៀងរាល់ដើមឆ្នាំសិក្សា។

គិតជាមធ្យមប្រចាំឆ្នាំ ភាគច្រើននៃសិស្សរៀនក្នុងថ្នាក់ទី១២ គឺបានចាប់យកផ្នែកស្ទែមដែលមានចំនួន ៥៣.៨% ក្នុងចន្លោះឆ្នាំ២០១៦ និងឆ្នាំ២០២០ (រូបភាពទី ៤.៤)។ ទោះបីយ៉ាងណាក៏ដោយ សមាមាត្រសិស្សផ្នែកស្ទែមក្នុងថ្នាក់ទី១២ បង្ហាញពីនិន្នាការធ្លាក់ចុះពី ៨០% នៅឆ្នាំ២០១៦ ទៅ ៣៦%នៅឆ្នាំ២០២០ (រូបភាពទី ៤.៤)។ ផ្ទុយទៅវិញ ការចាប់អារម្មណ៍របស់សិស្សមិនមែនផ្នែកស្ទែមបានកើនឡើងពីប្រមាណ ២០% ក្នុងឆ្នាំ២០១៦ ទៅ ៦៤% ក្នុងឆ្នាំ២០២០ (រូបភាពទី ៤.៤)។ នៅក្នុងលក្ខខណ្ឌតុល្យភាពយេនឌ័រនៃសិស្សស្ទែមក្នុងថ្នាក់ទី១២ សមាមាត្រសិស្សស្រីធៀបនឹងសិស្សស្ទែមសរុបបានកើនឡើងរៀងរាល់ឆ្នាំ និងមានតុល្យភាពក្នុងឆ្នាំ២០១៨ និង២០១៩ ហើយបានកើនឡើងខ្ពស់បន្តិចក្នុងឆ្នាំ ២០២០ (៦០%) (រូបភាពទី ៤.៥)។ គួរកត់សម្គាល់ផងដែរថាភាគរយសិស្សស្ទែមត្រូវបានគណនាដោយផ្អែកតាមទិន្នន័យនៃចំនួនសិស្សសរុបដែលបានប្រមូលអំឡុងឬបន្ទាប់ពាក់កណ្ដាលនៃឆ្នាំសិក្សា។




រូបភាពទី ៤.២៖ ចំនួនសមាមាត្រសិស្សផ្នែកស្ទែមនិងមិនមែនស្ទែមក្នុងថ្នាក់ទី ១១ គិតជាភាគរយ




រូបភាពទី ៤.៣៖ ចំនួនសមាមាត្រសិស្សស្រីផ្នែកស្ទែមក្នុងថ្នាក់ទី ១១ គិតជាភាគរយ

ដោយពិចារណាលើសូចនាករដែលបានកំណត់ក្នុងផែនទីបង្ហាញផ្លូវ **វ.ប.ន.** កម្ពុជា ២០៣០ ក្នុងការសម្រេចឱ្យបាន ៥០% នៃនិស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកស្ទែម ដែលក្នុងនោះ ៤០% ជាស្ត្រីនៅឆ្នាំ២០៣០ ការសម្រេចគោលដៅនេះគឺស្ថិតក្នុងការព្រួយបារម្ភណ៍ចំពោះតួអង្គពាក់ព័ន្ធ **វ.ប.ន.** ដោយសារតែចំនួនសិស្សស្ទែមទាំងថ្នាក់ទី១១

និងទី១២ បានបង្ហាញពីនិន្នាការធ្លាក់ចុះ។ ការណ៍នេះតម្រូវឱ្យមានការយកចិត្តទុកដាក់ ហើយអំពាវនាវឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាពីគ្រប់ភាគីពាក់ព័ន្ធដើម្បីបង្កើនចំណាប់អារម្មណ៍ ឬការចុះឈ្មោះចូលរៀនផ្នែកស្ទែមនៅកម្រិតវិទ្យាល័យ។




រូបភាពទី ៤.៤៖ ចំនួនសមាមាត្រសិស្សផ្នែកស្ទែមនិងមិនមែនស្ទែមក្នុងថ្នាក់ទី ១២ គិតជាភាគរយ




រូបភាពទី ៤.៥៖ ចំនួនសមាមាត្រសិស្សស្រីផ្នែកស្ទែមក្នុងថ្នាក់ទី ១២ គិតជាភាគរយ

ចំនួនសិស្សដែលបានរៀនចប់ថ្នាក់ទី១២ បានកើនឡើងរៀងរាល់ឆ្នាំចន្លោះពីឆ្នាំ ២០១៦ និង ២០១៩ ប៉ុន្តែបានកើនឡើងខ្លាំងបន្តិចនៅក្នុងឆ្នាំ២០២០ (រូបភាពទី ៤.៦)។ បើប្រៀបធៀបចំនួនសិស្សសរុបថ្នាក់ទី១២ ចំនួនសិស្សដែលបានរៀនចប់ថ្នាក់ទី១២ មានចំនួនពី ៤៨% ទៅ ៦០% នៅចន្លោះឆ្នាំ២០១៦ និងឆ្នាំ២០១៩ និង ៨៧% ក្នុងឆ្នាំ ២០២០ ខណៈដែលចំនួនសិស្សស្រីដែលបានបញ្ចប់ថ្នាក់ទី១២ (២០១៦-២០២០) មានចំនួនពី ៥១% ទៅ ៧៣%។ អំឡុងឆ្នាំ២០២០ ជំងឺរាតត្បាតជាសកលកូវីដ ១៩ បានរំខានដល់វិស័យអប់រំទូទាំងពិភពលោក រួមទាំងប្រទេស កម្ពុជាផងដែរ ហើយសិស្សមិនអាចចូលរៀនក្នុងថ្នាក់ដោយផ្ទាល់បានទេ ប៉ុន្តែពួកគេត្រូវទទួលយកការរៀនតាមប្រព័ន្ធអនឡាញ។ សិស្ស និងគ្រូបង្រៀនបានប្រឈមមុខនឹងភាពលំបាក និងបញ្ហាប្រឈមជាច្រើនក្នុងការរៀននិងបង្រៀនតាមប្រព័ន្ធអនឡាញក្នុងអំឡុងពេលនោះ។ ដូច្នេះ ក្រសួងអប់រំ យុវជន និងកីឡា បានសម្រេច និងអនុញ្ញាតិឱ្យសិស្សថ្នាក់ទី ១២ ដែលបានដាក់ពាក្យសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ត្រូវជាប់ដោយស្វ័យប្រវត្តិតែគ្មាននិទ្ទេស។ នេះជាមូលហេតុមួយក្នុងចំណោមមូលហេតុផ្សេងទៀតដែលបណ្តាលឱ្យចំនួនភាគរយសិស្សដែលបានបញ្ចប់ថ្នាក់ទី១២មានការកើនឡើងនៅក្នុងឆ្នាំ២០២០។ លើសពីនេះទៀត លទ្ធផលនេះក៏បានឆ្លុះបញ្ចាំងពីសិស្សដែលបានប្រឡងធ្លាក់ ឬបោះបង់ការសិក្សាមានចំនួនចន្លោះពី ៤០% និង ៥០% ក្នុងចន្លោះឆ្នាំ ២០១៦ និង ២០១៩ ផងដែរ។




រូបភាពទី ៤.៦៖ ចំនួនសិស្សដែលបានបញ្ចប់ការសិក្សាថ្នាក់ទី ១២

## ៤.២. កម្រិតឧត្តមសិក្សា

សិស្សដែលបានបញ្ចប់កម្រិតវិទ្យាល័យបន្តចុះឈ្មោះចូលរៀនទាំងបរិញ្ញាបត្ររង (ចំនួន២-៣ឆ្នាំ) ឬបរិញ្ញាបត្រ (ចំនួន៤-៥ឆ្នាំ) នៅគ្រឹះស្ថានឧត្តមសិក្សា។ យោងតាមទិន្នន័យរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចន្លោះឆ្នាំ ២០១៦ និង ២០១៩ ចំនួននិស្សិតបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររងបានកើនឡើងជាមធ្យម

ប្រហែល ១០០០ នាក់ក្នុងមួយឆ្នាំ ប៉ុន្តែបានធ្លាក់ចុះនៅឆ្នាំ ២០២០ ខណៈដែលនិស្សិតស្រីបានបញ្ចប់ថ្នាក់បរិញ្ញាបត្ររងមានចំនួន ២៩% គិតជាមធ្យមនៃនិស្សិតសរុប (រូបភាពទី ៤.៧)។




រូបភាពទី ៤.៧៖ ចំនួននិស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររង (ប្រភពទិន្នន័យ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)




រូបភាពទី ៤.៨៖ ចំនួននិស្សិតដែលកំពុងសិក្សាក្នុងថ្នាក់បរិញ្ញាបត្រ

ចំនួននិស្សិតសរុបដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្របានកើនឡើងជារៀងរាល់ឆ្នាំពី ៤៣០៧៧នាក់ ក្នុងឆ្នាំ ២០១៦ ដល់ ៥២០៧៦នាក់ ក្នុងឆ្នាំ ២០២០ ខណៈដែលចំនួននិស្សិតផ្នែកស្ទែម បានកើនឡើងបន្តិចបន្តួចពីចន្លោះឆ្នាំ ២០១៦ ដល់ឆ្នាំ ២០១៩ និងបានថយចុះបន្តិចបន្តួចក្នុងឆ្នាំ ២០២០ (រូបភាពទី ៤.៨)។ ជាទូទៅ គេសង្កេតឃើញថាចំនួននិស្សិតដែលបានចុះឈ្មោះចូលរៀនក្នុងមុខវិជ្ជាដែលទាក់ទងនឹងស្ទែម មានប្រហែលមួយភាគបីនៃនិស្សិតសរុប ដែលជាមធ្យមមាននិស្សិតចំនួន ១៣៤៣៧នាក់ ក្នុងមួយឆ្នាំ នៅចន្លោះឆ្នាំ ២០១៦ និង ២០២០ (រូបភាពទី ៤.៨)។

បើប្រៀបធៀបទៅនឹងនិស្សិតបញ្ចប់ការសិក្សាសរុបក្នុងមុខវិជ្ជាដែលមិនមែនស្ទែម ចំនួននិស្សិតរៀនមុខវិជ្ជាស្ទែម ដែលបានបញ្ចប់ការសិក្សាពីគ្រឹះស្ថានឧត្តមសិក្សានៅតែមានកម្រិតទាប (រូបភាពទី ៤.៩) ។ ចំនួនមធ្យមនៃនិស្សិតរៀនផ្នែកស្ទែម ដែលបានបញ្ចប់ការសិក្សាមានចំនួន ២៨៨៦នាក់ ក្នុងមួយឆ្នាំ នៅចន្លោះឆ្នាំ ២០១៦ និង ២០២០ (រូបភាពទី ៤.៩)។ គួរកត់សម្គាល់ផងដែរថា ទិន្នន័យនិស្សិតថ្នាក់បរិញ្ញាបត្រដែលទទួលបានមិនមានចំនួន ឬភាគរយនៃនិស្សិតស្រីនោះទេ។ ដូច្នេះ ការពិភាក្សាលើចំនួន ឬភាគរយរបស់និស្សិតស្រីមិនអាចធ្វើឡើងឬបង្ហាញបានទេនៅក្នុងផ្នែកនេះទេ។




រូបភាពទី ៤.៩៖ ចំនួននិស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ

បើគិតជាភាគរយ និស្សិតផ្នែកស្ទែមដែលកំពុងសិក្សានៅគ្រឹះស្ថានឧត្តមសិក្សាមានការប្រែប្រួលចន្លោះពី ២៤% ទៅ ៣២% ខណៈដែលនិស្សិតបញ្ចប់ការសិក្សាផ្នែកស្ទែម មានចន្លោះពី ១៥% ទៅ ១៨% នៃនិស្សិតសរុបរវាង

ឆ្នាំ ២០១៦ និង ២០២០ រៀងគ្នា (រូបភាពទី ៤.១០)។ ផ្អែកលើទិន្នន័យ និងទំនោរនេះ ចំនួនភាគរយនេះនៅតែមានគម្លាតឆ្ងាយពីសូចនាករគោលដៅដែលបានកំណត់នៅក្នុងផែនទីផ្លូវ ***វ.ប.ន.*** កម្ពុជា ២០៣០។




រូបភាពទី ៤.១០៖ ចំនួននិស្សិតផ្នែកស្ទែមដែលកំពុងសិក្សានិងបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ

ដូចគ្នានេះដែរ យោងតាមរបាយការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងឆ្នាំ ២០១៩ ការចុះឈ្មោះចូលរៀនមុខវិជ្ជាស្ទែម នៅក្នុងគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា នៅតែមានកម្រិតទាបគួរឱ្យកត់សម្គាល់។ វាជាកត្តាប្រឈមខ្លាំងចំពោះកម្ពុជាក្នុងការធ្វើឧស្សាហូបណីកម្ម ដូចដែលបានកំណត់ក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ឆ្នាំ ២០១៥-២០២៥ (RGC, ២០១៥; MoEYS, ២០១៧) ក៏ដូចជាផែនទីបង្ហាញផ្លូវ ***វ.ប.ន.*** កម្ពុជា ២០៣០ (MISTI, ២០២១)។ បើយោងតាមទិន្នន័យស្ថិតិ ជាង ៤០% នៃនិស្សិត ២០០០០០ នាក់ដែលបានចុះឈ្មោះចូលរៀនក្នុងឆ្នាំសិក្សា ២០១៧-២០១៨ បានជ្រើសរើសចុះឈ្មោះក្នុងកម្មវិធីសិក្សាដែលទាក់ទងនឹងធុរកិច្ច ហើយមានតែ ២៧% ប៉ុណ្ណោះដែលបានជ្រើសរើសយកកម្មវិធីសិក្សាទាក់ទងនឹងផ្នែកស្ទែម ដែលនៅក្នុងនោះវិស្វកម្មមានចំនួន ៨% បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន មានចំនួន ៧% វិទ្យាសាស្ត្រមូលដ្ឋានមានចំនួន ៥% សុខាភិបាលមានចំនួន ៤% និង កសិកម្មមានចំនួន ៣% (MoEYS, ២០១៩)។

## ៤.៣. កម្រិតក្រោយឧត្តមសិក្សា

ថ្នាក់ក្រោយឧត្តមសិក្សា សំដៅលើកម្រិតនៃការអប់រំលើសពីបរិញ្ញាបត្ររង ឬកម្រិតបរិញ្ញាបត្រ ដែលជាធម្មតាសំដៅលើសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឬបណ្ឌិត។ ចំនួននិស្សិតដែលកំពុងសិក្សាថ្នាក់ក្រោយឧត្តមសិក្សា ឬកម្រិតសមមូលពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២០ នៅកម្ពុជា ត្រូវបានបង្ហាញក្នុងរូបភាពទី ៤.១១។ ចំនួន

និស្សិតសរុបដែលកំពុងរៀនថ្នាក់ក្រោយឧត្តមសិក្សា បានកើនឡើងជាលំដាប់ពីប្រមាណ ១៥០០ នាក់ ក្នុងឆ្នាំ ២០១៦ ដល់ ២០១៩ ហើយបានថយចុះយ៉ាងខ្លាំងក្នុងឆ្នាំសិក្សា ២០២០។ ការថយចុះនេះមានចំនួនច្រើនជាង ៥០% ដែលបណ្តាលឱ្យចំនួននិស្សិតធ្លាក់ចុះពី ២៣២៥៦នាក់ ក្នុងឆ្នាំ២០១៩ មកត្រឹមតែ ៩៩៨៤នាក់ ក្នុងឆ្នាំ ២០២០។ លើសពីនេះទៅទៀត ចំនួននិស្សិតស្រីដែលសិក្សាថ្នាក់ក្រោយឧត្តមសិក្សាបានកើនឡើងពី ៤១១៩ នាក់ក្នុងឆ្នាំ ២០១៦ ដល់ ៥៣៤៨ នាក់ក្នុងឆ្នាំ ២០១៩ ហើយបានធ្លាក់ចុះមកនៅត្រឹមតែ ២៩៩៥នាក់ ក្នុងឆ្នាំ ២០២០។ ការថយចុះចំនួននេះគឺប្រហែលជាបណ្តាលមកពីការផ្ទុះឡើងនៃជំងឺរាតត្បាតសកលកូវីដ-១៩ ដែលបានចាប់ផ្តើមកើតឡើងតាំងពីឆ្នាំ២០១៩ ហើយបានរាតត្បាតចូលមកប្រទេសកម្ពុជានៅដើមឆ្នាំ ២០២០។ បើប្រៀបធៀបទៅនឹងចំនួននិស្សិតសរុបក្នុងកម្រិតក្រោយឧត្តមសិក្សា ភាគរយនៃនិស្សិតស្រីនៅថេរចាប់ពីឆ្នាំ ២០១៦ ដល់ ២០១៧ គឺត្រឹម ២២% បន្ទាប់មកកើនឡើងប្រហែល ១% នៅក្នុងឆ្នាំ ២០១៨ ហើយនៅដដែលក្នុងឆ្នាំបន្ទាប់ (២០១៩) គឺត្រឹម ២៣%។ គេចាប់អារម្មណ៍ឃើញថា ចំនួននេះបានកើនឡើងយ៉ាងខ្លាំងដល់កម្រិតខ្ពស់បំផុតគឺ ៣០% ក្នុងឆ្នាំ ២០២០។ បើប្រៀបធៀបទៅនឹងសូចនាករគោលដៅដែលបានកំណត់នៅក្នុងសសរស្តម្ភការកសាងមូលធនមនុស្សសម្រាប់វិស័យ *វ.ប.ន.* នៃផែនទីបង្ហាញផ្លូវ *វ.ប.ន.* កម្ពុជា ២០៣០ ដែលមាន ៥០% នៃនិស្សិតបញ្ចប់ការសិក្សានៅគ្រឹះស្ថានឧត្តមសិក្សាក្នុងផ្នែកស្ទែម គេសង្កេតឃើញថាភាគរយទាំងនេះគឺនៅឆ្ងាយពីគោលដៅនៅឡើយ (MISTI, ២០២១)។ ទោះជាយ៉ាងនេះក្តី ការវិភាគទិន្នន័យខាងលើនេះទៅតាមមុខវិជ្ជាដែលនិស្សិតជ្រើសរើសសិក្សា គួរតែត្រូវបានសិក្សា និងពិភាក្សាស៊ីជម្រៅបន្ថែម ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីមូលហេតុ និងបញ្ហាប្រឈម សំដៅផ្តល់នូវអនុសាសន៍និងផែនការសកម្មភាពនានាក្នុងការជំរុញនិងបង្កើនការចំណាប់អារម្មណ៍របស់សិស្ស និស្សិត ក៏ដូចជា សាធារណជនលើផ្នែកស្ទែម។




រូបភាពទី ៤.១១៖ ចំនួននិស្សិតដែលកំពុងសិក្សាថ្នាក់ក្រោយឧត្តមសិក្សាចាប់ពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០២០

រូបភាពទី ៤.១២ និងរូបភាពទី ៤.១៣ បង្ហាញពីចំនួននិស្សិតស្រីសរុប និងនិស្សិតសរុបផ្នែកស្នែម ក្នុងកម្រិតក្រោយឧត្តមសិក្សាពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២០។ ចំនួននិស្សិតសរុបថ្នាក់ក្រោយឧត្តមសិក្សាផ្នែកស្នែម បានកើនឡើងជាលំដាប់ពី ១៦៤០នាក់ ក្នុងឆ្នាំ ២០១៦ ដល់ ៣៤១១នាក់ ក្នុងឆ្នាំ២០១៩ នៅមុនពេលនៃការផ្ទុះឡើងនៃជំងឺរាតត្បាតជាសកល ហើយចំនួននេះ បានថយចុះមកត្រឹមតែ ១២៩៦នាក់ ក្នុងឆ្នាំ២០២០ (រូបភាពទី ៤.១៣)។ តាមរយៈទិន្នន័យនេះ គេសង្កេតឃើញថា ភាគរយនៃនិស្សិតបញ្ចប់ការសិក្សាផ្នែកស្នែម មានត្រឹមតែប្រមាណ ៨.៨-១៣% បើធៀបនឹងចំនួននិស្សិតសរុប។ ក្នុងចំណោមនិស្សិតបញ្ចប់ការសិក្សាផ្នែកស្នែមទាំងនោះ មានតែប្រហែល១០.៧-២១% ប៉ុណ្ណោះដែលជាស្ត្រី (រូបភាពទី ៤.១៣)។ ទោះបីជាភាគរយកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំក៏ដោយ វាច្បាស់ណាស់ថានៅមានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើដើម្បីបង្រួញគម្លាតយេនឌ័រនៅក្នុងមុខវិជ្ជាស្នែមនេះ។




រូបភាពទី ៤.១២៖ ចំនួននិស្សិតផ្នែកស្នែម និងចំនួននិស្សិតសរុបកំពុងសិក្សាក្នុងថ្នាក់ក្រោយឧត្តមសិក្សា




រូបភាពទី ៤.១៣៖ ចំនួននិស្សិតស្រីនិងចំនួននិស្សិតផ្នែកស្នែមសរុបកំពុងសិក្សាក្នុងថ្នាក់ក្រោយឧត្តមសិក្សា

ចាប់ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២០ មាននិស្សិតសរុបចំនួន ២០០៩៤នាក់ បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឬបណ្ឌិត (រូបភាពទី ៤.១៤) ។ របាយតួលេខប្រចាំឆ្នាំរបស់និស្សិតបញ្ចប់ការសិក្សាមានការប្រែប្រួល ដែលតួលេខខ្ពស់បំផុតគឺនៅក្នុងឆ្នាំ ២០១៩ និងតួលេខទាបបំផុតគឺក្នុងឆ្នាំ ២០២០។ ជាមធ្យម គេសង្កេតឃើញថាមានតែ ៨% នៃនិស្សិតបញ្ចប់ការសិក្សាសរុបទេដែលបានសញ្ញាបត្រផ្នែកស្ទែម ដែលក្នុងនោះមាន ១៦% ជាស្ត្រី។




រូបភាពទី ៤.១៤៖ ចំនួននិស្សិតដែលបានបញ្ចប់ការសិក្សាក្នុងថ្នាក់ក្រោយឧត្តមសិក្សាចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ ២០២០

## ៤.៤. ការអប់រំក្រៅប្រព័ន្ធ

ការអប់រំក្រៅប្រព័ន្ធ (ឧ. ជីវេត) មានគោលបំណងធានាថា កុមារទាំងអស់ រួមទាំងជនពិការ ឬជនដែលមានការលំបាកផ្នែកហិរញ្ញវត្ថុ ទទួលបានសិទ្ធិនិងការអប់រំមូលដ្ឋាន។ ការអប់រំក្រៅប្រព័ន្ធក៏ផ្តល់ឱកាសដល់ប្រជាជនក្នុងការទទួលបានបំនិនជីវិត និងក្លាយជាអក្ខរជនផងដែរ (Voleak, ២០២១)។ ចាប់ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២០ សិស្សហូតដល់ ១៦៦៩០៤នាក់ បានបញ្ចប់ការសិក្សាតាមរយៈការអប់រំក្រៅប្រព័ន្ធនេះនៅទូទាំងប្រទេសដែលមានសិស្សស្រីជាមធ្យម ៥២% បើប្រៀបធៀបទៅនឹងសិស្សដែលបានបញ្ចប់ការសិក្សាសរុប។ ចំនួនសិស្សដែលបានបញ្ចប់ការសិក្សាតាមរយៈការអប់រំក្រៅប្រព័ន្ធត្រូវបានគេសង្កេតឃើញថាមានការកើនឡើងយ៉ាងខ្លាំងនៅក្នុងឆ្នាំ ២០១៨ និង ២០១៩ (រូបភាពទី ៤.១៥)។




រូបភាពទី ៤.១៥៖ ចំនួនសិស្សស្រីនិងសរុបដែលបានបញ្ចប់ការសិក្សាការអប់រំក្រៅប្រព័ន្ធ

## ៤.៥. ទិន្នន័យធនធានមនុស្សជាអ្នកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

ការគ្រប់គ្រងទិន្នន័យធនធានមនុស្សឱ្យបានត្រឹមត្រូវពិតជាមានសារៈសំខាន់ណាស់ ចំណែកឯវិធីសាស្ត្រ ឬប្រព័ន្ធសារពើភ័ណ្ឌត្រឹមត្រូវមួយអាចធ្វើឱ្យមានផលចំណេញនិងជួយដល់ការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ធនធានមនុស្ស។ ដំណើរឆ្ពោះទៅកាន់ភាពជឿនលឿនទៅមុខនៃវិស័យ **វ.ប.ន.** នៅប្រទេសកម្ពុជា បញ្ជីទិន្នន័យធនធានមនុស្ស(បញ្ជីសារពើភ័ណ្ឌ)ជាអ្នកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាកម្ពុជា ត្រូវបានបង្កើតឡើង និងធ្វើបច្ចុប្បន្នភាពតាមពេលវេលាកំណត់ ដោយវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍(**វ.ជ.វ.ប.ន.**)។ គិតត្រឹមថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ក្រសួង-ស្ថាប័នចំនួន២៣ បានឆ្លើយតប និងផ្ញើទិន្នន័យមក **វ.ជ.វ.ប.ន.** មានដូចជា៖ ១) ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI), ២) ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (MPTC), ៣) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF), ៤) ក្រសួងទេសចរណ៍ (MoT), ៥) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF), ៦) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT), ៧) ក្រសួងការពារជាតិ, ៨) ក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច, ៩) ក្រសួងសុខាភិបាល (MoH), ១០) ក្រសួងធម្មការ និងសាសនា, ១១) ក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ (MCFA), ១២) ក្រសួងរ៉ែ និងថាមពល (MME), ១៣) ក្រសួងអភិវឌ្ឍន៍ជនបទ (MRD), ១៤) រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល (SSCA), ១៥) ក្រសួងធនធានទឹក និងឧតុនិយម (MoWRAM), ១៦) ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (MFAIC), ១៧) ក្រសួងមុខងារសាធារណៈ, ១៨) ក្រសួងបរិស្ថាន (MoE), ១៩) សាលាខេត្តតាកែវនៅក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃ (MoI), ២០) សភាពាណិជ្ជកម្មកម្ពុជា (CCC), ២១) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ២២) ក្រសួងសាធារណ

ការ និងដឹកជញ្ជូន (MPWT), និង ២៣) ក្រសួងផែនការ (MoP)។ ធនធានមនុស្សជាអ្នកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាកម្ពុជាមានសរុបចំនួន ១០៨៨៥ រូប (២៤% ជាស្ត្រី) ដែលក្នុងនោះសញ្ញាបត្របណ្ឌិតមានចំនួន ៧៣១ រូប (ស្មើនឹង ៦.៧២%) សញ្ញាបត្រវេជ្ជបណ្ឌិតមានចំនួន ៧៩០ រូប (ស្មើនឹង ៧.២៥%) សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ១៥៧៦ (ស្មើនឹង ១៤.៤៨%) និងសញ្ញាបត្របរិញ្ញាបត្រមានចំនួន ៧៧៨៨ រូប (ស្មើនឹង ៧១.៥៥%)។ ការបែងចែកធនធានមនុស្សជាស្ត្រី និងបុរសតាមកម្រិតសញ្ញាបត្របង្ហាញនៅក្នុងរូបភាពទី៤.១៦។




រូបភាពទី ៤.១៦៖ ការប្រៀបធៀបកម្រិតសញ្ញាបត្រ និងភេទ

ស្តង់ដារអន្តរជាតិនៃចំណាត់ថ្នាក់ការសិក្សា (ISCED)ដែលបង្កើតឡើងដោយអង្គការយូណេស្កូ ត្រូវបានយកប្រើជាក្របខ័ណ្ឌក្នុងការប្រមូលផ្តុំ ចងក្រង និងវិភាគស្ថិតិប្រៀបធៀបទូទាំងប្រទេស។ ជាគោលការណ៍ ចំណាត់ថ្នាក់នេះត្រូវបានរចនាឡើងដើម្បីពណ៌នា និងបែងចែកចំណាត់ថ្នាក់ឯកទេសនៃការអប់រំ និងបណ្តុះបណ្តាលនៅមធ្យមសិក្សា ឧត្តមសិក្សា និងក្រោយឧត្តមសិក្សាដែលមានកម្មវិធីស្របតាមគុណវុឌ្ឍិជាតិនៃការអប់រំក្នុងប្រព័ន្ធ។ ឋានានុក្រមបីកម្រិតនៃឯកទេសមានដូចជា កម្រិតធំទូលាយទូទៅ (ខ្ពស់បំផុត) កម្រិតបង្រួម (កម្រិតទី២) និងកម្រិតជាក់លាក់ (កម្រិតទី៣) ត្រូវបានប្រើប្រាស់នៅក្នុងចំណាច់ថ្នាក់ស្តង់ដារអន្តរជាតិនៃការអប់រំ។ រូបភាពទី៤.១៧ បង្ហាញពីចំនួនធនធានមនុស្សជាអ្នកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាតាមឯកទេសនៃការអប់រំ និងការបណ្តុះបណ្តាល។




រូបភាពទី ៤.១៧៖ ធនធានមនុស្សអ្នកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាតាមឯកទេស

## ៥. វឌ្ឍនភាពនៃវិស័យ វ.ប.ន.

### ៥.១. គម្រោង/កិច្ចសហការក្នុងវិស័យ វ.ប.ន.

បន្ទាប់ពីបានបង្កើតក្រសួង **ឧ.វ.ប.ន.** និង **ក.ជ.វ.ប.ន.** ដោយព្រះរាជក្រម រាជរដ្ឋាភិបាលបានផ្តល់សមត្ថកិច្ចដល់ក្រសួង **ឧ.វ.ប.ន.** ក្នុងការសម្របសម្រួលកិច្ចការផ្សេងៗដែលបម្រើឱ្យវឌ្ឍនភាពនៃវិស័យ **វ.ប.ន.** ក្នុងព្រះរាជាណាចក្រកម្ពុជា។ មានគម្រោង/កិច្ចសហការជាង ៤០០ ត្រូវបាននិងកំពុងអនុវត្តដោយក្រសួង-ស្ថាប័នទាំងឡាយសម្រាប់រយៈពេលប្រាំឆ្នាំចុងក្រោយនេះ បើយោងតាមទិន្នន័យដែលផ្តល់ដោយសមាជិករបស់ **ក.ជ.វ.ប.ន.**។ គម្រោង/កិច្ចសហការក្នុងវិស័យ **វ.ប.ន.** រាប់បញ្ចូលទាំងសកម្មភាពដែលមានលក្ខណៈស្រាវជ្រាវនិងអភិវឌ្ឍន៍ និងការប្រើ **វ.ប.ន.** ដើម្បីអនុវត្តគោលនយោបាយផ្សេងៗ។ គម្រោង/កិច្ចសហការដែល បាននិងកំពុងអនុវត្តដោយក្រសួង-ស្ថាប័នច្រើនជាងគេគឺ MOEYS ( ១០៩ ), បន្ទាប់មក MPTC ( ៧៤ ), MCFA ( ៦៦ ), MoE ( ៤០ ), MoI ( ២៨ ), MPWT ( ២៥ ), MAFF ( ២២ ), MISTI ( ១៧ ), MoH ( ១៣ ), MEF ( ១២ ), CCC ( ១០ ), MFAIC ( ៩ ), MLVT ( ៩ ), MoT ( ៨ ), SSCA ( ៣ ), និង MRD ( ១ )។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC), ក្រសួងដែនដី និងនគរូបនីយកម្ម (MLMUPC), ក្រសួងព័ត៌មាន (MoInfo), ក្រសួងយុត្តិធម៌ (MoJ), MoP, MoWRAM, ទីស្តីការគណៈរដ្ឋមន្ត្រី (OCM), និង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) ត្រូវបានសន្មតថាមិនបានផ្ញើទិន្នន័យ ឬមិនមានគម្រោង/កិច្ចសហការលើវិស័យ **វ.ប.ន.** (រូបភាពទី ៥.១) មកលេខាធិការដ្ឋាននៃ **ក.ជ.វ.ប.ន.**។ បើយោងតាមទិន្នន័យដែលប្រមូលបាន គ្រឹះស្ថានឧត្តមសិក្សាដែលស្ថិតក្រោមសមត្ថកិច្ចរបស់ ក្រសួងអប់រំ យុវជន និងកីឡា មានការចូលរួមច្រើនក្នុងការអភិវឌ្ឍវិស័យ **វ.ប.ន.** (រូបភាពទី ៥.១)។ ជាក់ស្តែង ចំនួនគម្រោងទាំងនេះឆ្លុះ បញ្ចាំងពីការអនុវត្ត «គម្រោងកែលម្អការអប់រំឧត្តមសិក្សា» របស់ក្រសួង

អប់រំ យុវជន និងកីឡាដែលមានថវិកាចំនួន ៩២.៥ លានដុល្លារសហរដ្ឋអាមេរិកជាកម្ចីពីធនាគារពិភពលោក និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលដើម្បីអភិវឌ្ឍស្ទែមក្នុងអនុវិស័យឧត្តមសិក្សា។ គម្រោងនេះមានគោលដៅបង្កើនធនធានមនុស្សដែលមានជំនាញខ្ពស់លើផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងការស្រាវជ្រាវនិងអភិវឌ្ឍន៍។ ការរួមចំណែកចម្បងលំដាប់ទី២ដល់ការអភិវឌ្ឍ **វ.ប.ន.** តាមរយៈការអនុវត្តគម្រោងគឺ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ ការបង្កើតឱ្យមានមូលនិធិកសាងសមត្ថភាពស្រាវជ្រាវ និងអភិវឌ្ឍន៍ចាប់ពីឆ្នាំ២០១៧ អាចជាមូលហេតុចម្បងមួយដែលបណ្ដាលឱ្យមានគម្រោង/កិច្ចសហការច្រើននៅក្រសួងនេះ។ ជាងនេះទៅទៀត ក្រសួង ក្រសួង វប្បធម៌ និងវិចិត្រសិល្បៈបានរួមចំណែកចម្បងលំដាប់ទី៣ក្នុងកិច្ចការអនុវត្តន៍ និងប្រើប្រាស់បច្ចេកវិទ្យា និងឧបករណ៍វិទ្យាសាស្ត្រក្នុងគម្រោង/កិច្ចសហការដើម្បីសិក្សាស្រាវជ្រាវផ្នែកបុរាណវិទ្យា និងការថែរក្សាតំបន់បេតិកភណ្ឌជាតិនិងសាកលលោកក្នុងព្រះរាជាណាចក្រកម្ពុជា។ ប្រព័ន្ធបច្ចេកវិទ្យាផ្សេងៗដែលត្រូវបានប្រើប្រាស់រួមមាន៖ ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) បច្ចេកវិទ្យាឡាយដារ(LiDar) និងប្រព័ន្ធកំណត់ទីតាំងសាកល (GPS)។ ក្រសួងផ្សេងទៀតបាន និងកំពុងអភិវឌ្ឍប្រព័ន្ធអេឡិកត្រូនិកសម្រាប់គ្រប់គ្រងទិន្នន័យ សេវាកម្មអនឡាញជាសាធារណៈ ការចុះបញ្ជី ការធ្វើអធិការកិច្ចគេហទំព័រ បណ្ណាល័យអេឡិចត្រូនិក ការគ្រប់គ្រងវិនិយោគនិងពាណិជ្ជកម្ម ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងពន្ធគយ ការគ្រប់គ្រងព័ត៌មានសុខភាព ការគ្រប់គ្រងព័ត៌មានធនធានមនុស្ស ។ល។ សូមកំណត់ចំណាំថាទិន្នន័យទាំងនេះមិនរាប់បញ្ចូលវិស័យឯកជនទេ។




រូបភាពទី ៥.១៖ ចំនួនគម្រោង/កិច្ចសហការដែលទាក់ទងនឹង **វ.ប.ន.**។ លេខសូន្យមានន័យថាក្រសួងមិនមានគម្រោង/កិច្ចសហការក្នុងវិស័យ **វ.ប.ន.** ឬមិនបានផ្ដល់ព័ត៌មាន។

## ៥.២ កិច្ចសហការជាមួយអ្នកពាក់ព័ន្ធ

យោងតាមព័ត៌មានផ្ដល់ឱ្យដោយក្រសួង-ស្ថាប័នដែលជាសមាជិករបស់ **ក.ជ.វ.ប.ន.** គម្រោងដែលមានលក្ខណៈសហការភាគច្រើនត្រូវបានអនុវត្តក្នុងកំឡុងពេលប្រាំឆ្នាំចុងក្រោយនេះដោយមានការចូលរួមពីដៃគូអភិវឌ្ឍន៍ វិស័យឯកជន អង្គការក្រៅរដ្ឋាភិបាល និងគ្រឹះស្ថានឧត្តមសិក្សា។ ប្រមាណពីរភាគបីនៃគម្រោង/កិច្ចសហការដែល

ប្រមូលបានត្រូវបានអនុវត្តក្នុងកម្រិតជាតិ (ប្រមាណ៦៧%) និងប្រមាណមួយភាគបីធ្វើឡើងក្នុងកម្រិតសហការតំបន់ (៣%)និងអន្តរជាតិ(៣០%) (រូបភាពទី ៥.២)។







រូបភាពទី ៥.២៖ ប្រភេទ និងស្ថានភាពនៃគម្រោង/កិច្ចសហការដែលពាក់ព័ន្ធនឹង **វ.ប.ន.**

## ៥.៣. ការស្រាវជ្រាវ និងអភិវឌ្ឍន៍

សកម្មភាពនៃការការស្រាវជ្រាវ និងអភិវឌ្ឍន៍ មិនត្រូវបានគេសង្កេតឃើញនិងអនុវត្តយ៉ាងទូលំទូលាយនៅក្នុងបណ្ដាក្រសួង-ស្ថាប័នទាំងអស់ខាងលើនោះទេពីព្រោះ ការស្រាវជ្រាវ និងអភិវឌ្ឍន៍មិនមែនជាសកម្មភាពស្នូលរបស់ក្រសួង-ស្ថាប័ន។ បើតាមព័ត៌មានប្រមូលដោយ ក្រសួងអប់រំ យុវជន និងកីឡា គម្រោងស្រាវជ្រាវ និងអភិវឌ្ឍន៍ភាគច្រើនត្រូវបានអនុវត្តនៅគ្រឹះស្ថានឧត្តមសិក្សានានាដែលជាគម្រោងកិច្ចសហការជាមួយដៃគូនានា (រូបភាពទី ៥.២)។ គម្រោងសហការទាំងនោះ ភាគច្រើនត្រូវបានអនុវត្តក្រោមគម្រោងកម្ចីហិរញ្ញប្បទានរបស់ធនាគារពិភពលោក (ឧទាហរណ៍ គម្រោងកែលម្អការអប់រំឧត្តមសិក្សា) ហើយគម្រោងស្រាវជ្រាវមួយចំនួនទៀតត្រូវបានសហការ និងគាំទ្រដោយដៃគូអភិវឌ្ឍន៍ឬគ្រឹះស្ថានឧត្តមសិក្សា។

គួររំលឹកនិងបញ្ជាក់ផងដែរថា ការកសាងរបៀបវារៈស្រាវជ្រាវជាតិកំពុងត្រូវបានរៀបចំនិងសម្របសម្រួលដោយក្រសួង **ឧ.វ.ប.ន.** ក្នុងគោលដៅកំណត់អ្វីទៅជាអាទិភាពនៃការស្រាវជ្រាវដើម្បីសម្រេចបានបេសកកម្មរបស់ប្រទេស (ដូចដែលបានរៀបរាប់ក្នុងផ្នែកទី ៣ ខាងលើ)។ របៀបវារៈដែលបានកំណត់ និងផ្ដល់តម្លៃបំពេញបន្ថែម និងទិសដៅលើការស្រាវជ្រាវដែលមានស្រាប់ទាំងនេះ។ លទ្ធផលនៃការកសាងរបៀបវារៈស្រាវជ្រាវជាតិនឹងត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាល និងស្ថាប័នស្រាវជ្រាវ ដើម្បីណែនាំតម្រង់ទិសស្រាវជ្រាវរបស់ពួកគេ។ ក្រមសីលធម៌ការស្រាវជ្រាវត្រូវបានព្រាង និងពិគ្រោះយោបល់តាមរយៈសិក្ខាសាលាអនឡាញជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនានាក្នុងការពង្រឹងគុណភាពនៃការស្រាវជ្រាវបន្ថែមផងដែរ។ ក្នុងក្របខ័ណ្ឌគណៈកម្មាធិការអាស៊ាន ស្ដីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ASEAN-COSTI) លេខាធិការដ្ឋានរបស់កម្ពុជាបាននឹងកំពុងខិតខំប្រឹងប្រែងបង្កើតអនុគណៈកម្មាធិការនិងរចនាសម្ព័ន្ធសមរម្យ ដែលមានសមាសភាព

ចូលរួមពីរាជរដ្ឋាភិបាល និងអ្នកសិក្សាស្រាវជ្រាវ ដើម្បីធ្វើការសហការជាមួយប្រទេសក្នុងតំបន់ក្នុងក្របខ័ណ្ឌ ASEAN-COSTI ជាពិសេស ការងារនិងសកម្មភាពដែលទាក់ទងនឹងការស្រាវជ្រាវ និងអភិវឌ្ឍន៍។ ជាឧទាហរណ៍ របៀបវារៈចំនួនពីរស្តីពីការប្រយុទ្ធប្រឆាំងនឹង កូវីដ១៩ និងបរិវត្តកម្មឌីជីថលក្នុងឧស្សាហកម្មកម្មន្តសាលត្រូវបានអនុម័តដោយកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ក្នុងឆ្នាំ ២០២១។ គួររំលឹកថាផងដែរថា ១% នៃផលិតផលក្នុងស្រុកសរុប គួរតែត្រូវបានប្តេជ្ញាវិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍន៍នៅត្រឹមឆ្នាំ ២០៣០ ដើម្បីសម្រេចបាននូវសូចនាករដែលបានកំណត់នៅក្នុង ផែនទីបង្ហាញផ្លូវ **វ.ប.ន.** កម្ពុជា ២០៣០។

## ៥.៤. ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផែនទីបង្ហាញផ្លូវ វ.ប.ន.កម្ពុជា ២០៣០

ក្រសួង**ឧ.វ.ប.ន.** បានបង្កើតនាយកដ្ឋាន តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ តាមប្រកាសលេខ ២៣២ ចុះថ្ងៃទី១១ សីហា ឆ្នាំ២០២០ ដែលមានគោលបំណងដូចតទៅ៖ ១)រៀបចំយន្តការ និងផែនការការងារ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ, ២)កំណត់សូចនាករជាក់លាក់(ក្នុងរយៈពេលខ្លី មធ្យម និងវែង) សម្រាប់ធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការមេ គម្រោង ផែនការសកម្មភាព និងផែនការ **វ.ប.ន.** ផ្សេងៗទៀត សម្រាប់ថ្នាក់ដឹកនាំធ្វើការសម្រេចចិត្ត, ៣)ចូលរួមបង្កើតការវាយតម្លៃលើបុគ្គល និងស្ថាប័ន **វ.ប.ន.** ដែលមានស្នាដៃ, ៤)ចែករំលែក លទ្ធផលនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយ **វ.ប.ន.**, និង ៥)កៀរគរថវិកា/មូលនិធិដើម្បីគាំទ្រនាយកដ្ឋាន។ តាមរយៈការបង្កើតនាយកដ្ឋាននេះ ជាឱកាសមួយដ៏ល្អដែលការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃត្រូវបានបង្កើតឡើងស្របពេលដែលមានវត្តមានរបស់ក្រសួង **ឧ.វ.ប.ន.** ខណៈដែលក្រសួងជាច្រើនមិនមានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ក្នុងការដឹកនាំការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនៅឡើយ។ នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ នឹងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តគោលនយោបាយផ្សេងៗ ដូច្នេះផែនទីបង្ហាញផ្លូវ **វ.ប.ន.** កម្ពុជា ២០៣០ ជាឯកសារមួយក្នុងចំណោមឯកសារគោលនយោបាយដែលត្រូវតែតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

ដើម្បីប្រាកដថាផែនទីបង្ហាញផ្លូវ **វ.ប.ន.** កម្ពុជា ២០៣០ នឹងត្រូវអនុវត្តតាមផែនការដែលបានគ្រោង ក្រសួង **ឧ.វ.ប.ន.** ដែលមាននាយកដ្ឋាន តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ **វ.ប.ន.** ជាសេនាធិការក្នុងការអនុវត្តនឹង ១)បង្កើតប្រព័ន្ធដើម្បីតាមដាន ត្រួតពិនិត្យ គោលដៅគោលនយោបាយសំខាន់ៗ សូចនាករ ធាតុចូល សកម្មភាព និងរាយការណ៍ប្រចាំឆ្នាំស្តីពី វឌ្ឍនភាព និងការអនុវត្ត ដើម្បីយកទៅពិភាក្សាក្នុងការប្រជុំរបស់ **ក.ជ.វ.ប.ន.**, ២)បង្កើតភាពជាដៃគូរវាងក្រសួង **ឧ.វ.ប.ន.** និងវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការដើម្បីផ្លាស់ប្តូរទិន្នន័យ និងព័ត៌មានជាច្រើនទៅលើការអនុវត្តនវានុវត្តន៍ដោយវិស័យឯកជន និងសាធារណៈ។ សកម្មភាពជាដៃគូមានដូចជា ការដឹកនាំស្ទង់មតិនវានុវត្តន៍របស់សហគ្រាសជារៀងរាល់៣ ឬ៤ឆ្នាំម្តង និងការអនុវត្តវិធីសាស្ត្រគណនាស្តង់ដារអន្តរជាតិ និងការវាយតម្លៃនិងពិនិត្យឡើងវិញនូវផែនទីបង្ហាញផ្លូវ

**វ.ប.ន.** កម្ពុជា ២០៣០ ជារៀងរាល់៣ ឬ៤ឆ្នាំម្តង និងធ្វើការកែតម្រូវទៅតាមភាពចាំបាច់។ នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ បានប្រឹងប្រែងនិងកំណត់កម្មវិធីអាទិភាពដូចតទៅ៖

១) បង្កើតក្របខ័ណ្ឌ និងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីវាយតម្លៃការអនុវត្តផែនទីបង្ហាញផ្លូវ **វ.ប.ន.** កម្ពុជា ២០៣០។

២) បង្កើតសៀវភៅណែនាំតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ សម្រាប់តួអង្គពាក់ព័ន្ធនឹងវិស័យ **វ.ប.ន.**។

៣) បណ្តុះបណ្តាលមន្ត្រីថ្មីឱ្យយល់ដឹងពីមូលដ្ឋានគ្រឹះនៃប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ(វគ្គបណ្តុះបណ្តាលជាសេរី)។

៤) សម្រួលវិធីសាស្ត្រទាក់ទងទៅនឹងក្របខ័ណ្ឌ ផែនការ ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីធានាការអនុវត្តគោលនយោបាយ **វ.ប.ន.** ឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល។

៥) ប្រមូលទិន្នន័យ/ព័ត៌មានពីតួអង្គពាក់ព័ន្ធ ដើម្បីសរសេររបាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃផែនទីបង្ហាញផ្លូវ **វ.ប.ន.** កម្ពុជា ២០៣០។

៦) ដឹកនាំការប្រជុំគណៈគ្រប់គ្រងជាប្រចាំ(ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ) ដើម្បីតាមដាន និងត្រួតពិនិត្យ ការអនុវត្តផែនទីបង្ហាញផ្លូវ **វ.ប.ន.** កម្ពុជា ២០៣០។

៧) រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការសរសេររបាយការណ៍(របាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ)។

៨) ចូលរួមរៀបចំកិច្ចប្រជុំ **ក.ជ.វ.ប.ន.** (ពីរដងក្នុងមួយឆ្នាំ) ដើម្បីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនទីបង្ហាញផ្លូវ **វ.ប.ន.** កម្ពុជា ២០៣០។

៩) សរសេររបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំនៃការអនុវត្តផែនទីបង្ហាញផ្លូវ **វ.ប.ន.** កម្ពុជា ២០៣០ ដើម្បីដាក់ជូនក្រសួង **ឧ.វ.ប.ន.** និង**ក.ជ.វ.ប.ន.**។

បច្ចុប្បន្ននេះ នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ បានបង្កើតក្របខ័ណ្ឌលទ្ធផលដែលមានដូចជា៖ សូចនាករចំនួន ៣១ និងនិយមន័យ/ការបកស្រាយនៃសូចនាករនីមួយៗ បន្ទាត់មូលដ្ឋាន គោលដៅ និងតួអង្គពាក់ព័ន្ធដើម្បីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនទីបង្ហាញផ្លូវ **វ.ប.ន.** កម្ពុជា ២០៣០។ ការប្រជុំ និងសិក្ខាសាលា/សិក្ខាសាលាពិគ្រោះយោបល់ជាច្រើន ត្រូវបានធ្វើឡើងដើម្បីប្រមូលជាតុចូល ព័ត៌មាន/មតិយោបល់ត្រឡប់ និង អនុសាសន៍ ដើម្បីបង្កើត ដាក់បញ្ចូលគ្នា ធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌលទ្ធផល ឱ្យឆ្លើយតបទៅនឹងគោលដៅរបស់ផែនទីបង្ហាញផ្លូវ។ គ្រប់ផ្នែកទាំងអស់របស់ក្របខ័ណ្ឌលទ្ធផលត្រូវបានចម្រាញ់ និងជ្រើសរើសដោយយកចិត្តទុកដាក់។ លើសពីនេះទៅទៀត ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផែនទីបង្ហាញផ្លូវ **វ.ប.ន.** កម្ពុជា ២០៣០ ត្រូវបានបង្កើតឡើងដើម្បីប្រមូលទិន្នន័យជាប្រចាំពីតួអង្គពាក់ព័ន្ធតាមរយៈការតាមដាន ត្រួតពិនិត្យ និងប្រព័ន្ធរបាយការណ៍។ របាយការណ៍វឌ្ឍនភាពទាំងឡាយនឹងត្រូវផ្តល់ជូនដោយតួអង្គពាក់ព័ន្ធ ជាប្រចាំ(ឧទាហរណ៍ សម្រាប់ក្រសួង **ឧ.វ.ប.ន.** ជាប្រចាំខែ និងតួអង្គពាក់ព័ន្ធ

ផ្សេងទៀតជាប្រចាំត្រីមាស ឆមាស និងឆ្នាំ)។ នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ នៃក្រសួង **ឧ.វ.ប.ន.** នឹងចងក្រងរបាយការណ៍ដាក់បញ្ចូលគ្នា និងចុងក្រោយរាយការណ៍ជូន **ក.ជ.វ.ប.ន.** ដើម្បីធ្វើការសម្រេចចិត្ត។ របាយការណ៍ និងការប្រមូលទិន្នន័យ នឹងដាក់នៅក្នុងប្រព័ន្ធ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដែលគ្រោងផលិតក្នុងឆ្នាំ២០២១។ នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ បង្កើតសេចក្តីព្រាងនៃសៀវភៅណែនាំការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ និងរំហូរការងារនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរបស់នាយកដ្ឋាន ដើម្បីធានាបាននូវការប្រតិបត្តិនៃប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ និងរាយការណ៍ពីលទ្ធផលជូនអ្នកសម្រេចចិត្ត/ថ្នាក់ដឹកនាំឱ្យទាន់ពេលវេលា។ ស្តីពីការអភិវឌ្ឍសមត្ថភាព នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ បានធ្វើសិក្ខាសាលាចំនួន ៥ ជាសេរីស្តីពីការបង្កើតប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ **វ.ប.ន.**។ គោលបំណងនៃសិក្ខាសាលាទាំងនោះគឺផ្សព្វផ្សាយ និងកសាងសមត្ថភាពមន្ត្រីរបស់ក្រសួង **ឧ.វ.ប.ន.** គ្រប់កម្រិតថ្នាក់ ពីប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។ ដើម្បីធានាសមិទ្ធផល និងបង្កើតវប្បធម៌នៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ក្នុងអគ្គនាយកដ្ឋាន **វ.ប.ន.** ក៏ដូចជាក្រសួង **ឧ.វ.ប.ន.** ទាំងមូលត្រូវតែមានផែនការប្រចាំឆ្នាំ/ចវិកាច្បាស់លាស់ និងអនុវត្តដោយរលូនក្រោមប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

## ៦. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

របាយការណ៍នេះបានផ្តល់នូវបច្ចុប្បន្នភាពចុងក្រោយនៃវឌ្ឍនភាពនៃក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ និងភាពរីកចម្រើនដែលទាក់ទងទៅនឹងវិស័យ **វ.ប.ន.** រហូតដល់ឆ្នាំ២០២១។ ការប្រមូលទិន្នន័យ និងព័ត៌មាននៃការអនុវត្ត **វ.ប.ន.** ពីក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ជាពិសេសពីធនធានមនុស្សផ្គត់ផ្គង់ផ្នែកស្ទែម និងស្ថានភាពនៃគម្រោង/កិច្ចសហការលើវិស័យ **វ.ប.ន.** ដោយស្ថាប័នរដ្ឋាភិបាលត្រូវបានវិភាគដោយផ្អែកលើត្រីវិស័យដែលផ្តល់ដោយគោលនយោបាយជាតិ **វ.ប.ន.** ២០២០-២០៣០ និងផែនទីបង្ហាញផ្លូវ **វ.ប.ន.** កម្ពុជា ២០៣០។

មកដល់បច្ចុប្បន្ននេះ ចំនួនធនធានមនុស្សផ្តល់ដោយក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដែលមានសញ្ញាបត្របណ្ឌិត វេជ្ជបណ្ឌិត បរិញ្ញាបត្រជាន់ខ្ពស់ និងបរិញ្ញាបត្រមានចំនួន ១០ ៨៨៥នាក់ ក្នុងនោះស្ត្រីមាន២៥%។ ក្នុងចន្លោះឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២០ និស្សិតផ្នែកស្ទែមដែលបាននិងកំពុងសិក្សានៅគ្រឹះស្ថានឧត្តមសិក្សាប្រែប្រួលក្នុងចន្លោះ ២៤% ទៅ ៣២% ផ្ទុយទៅវិញចំនួននិស្សិតដែលបញ្ចប់ការសិក្សាផ្នែកស្ទែមគឺចន្លោះពី ១៥% ទៅ ១៨% តែប៉ុណ្ណោះក្នុងចន្លោះពេលដូចគ្នា។ ចំនួននិស្សិតសរុបនៅថ្នាក់ក្រោយឧត្តមសិក្សាកើនឡើងជាមធ្យមក្នុងរង្វង់ ១៥០០នាក់ ពីចន្លោះឆ្នាំ ២០១៦ ដល់ ២០១៩ និងបានធ្លាក់ចុះគួរឱ្យកត់សម្គាល់ក្នុងឆ្នាំសិក្សា ២០២០ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ចំណែកឯភាគរយនៃនិស្សិតស្រីនៅថ្នាក់ក្រោយឧត្តមសិក្សាប្រែប្រួលក្នុងរង្វង់ ២២% ទៅ ៣០% ក្នុងចន្លោះឆ្នាំ ២០១៦ និង

២០២០។ម្យ៉ាងវិញទៀត ការបណ្តុះបណ្តាលស្នែមនៅថ្នាក់ចំណេះទូទៅជាការណ៍ដែលត្រូវយកមកពិចារណា ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ។ និន្នាការនៃសិស្សមធ្យមសិក្សាចំណេះទូទៅដែលជ្រើសរើសស្នែមបាន បង្ហាញថាធ្លាក់ចុះ ចាប់ពីចន្លោះឆ្នាំ ២០១៦ ដល់២០២០។ នេះជាសារ/ការដាស់តឿនដល់តួអង្គពាក់ព័ន្ធនឹង **វ.ប.ន.** ទាំងអស់ គួរសិក្សាអង្កេតមើលដោយស៊ីជម្រៅដើម្បីបង្កើនចំណាប់អារម្មណ៍ថែមទៀតក្នុងចំណោម យុវជន។ ប្រសិនបើមិនមានចំនួនធនធានមនុស្សសំខាន់ៗជាច្រើនក្នុងវិស័យស្នែមទេ ទស្សនវិស័យរបស់យើង ដែលចង់ប្រែក្លាយខ្លួនទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងចំណូលខ្ពស់ត្រឹម ឆ្នាំ ២០៥០ អាចជួបការប្រឈមក្នុងការសម្រេចបាននូវចក្ខុវិស័យនេះ។

ក្រៅពីនេះចំនួនគម្រោង/កិច្ចសហការដែលទាក់ទងនឹងការស្រាវជ្រាវនិងអភិវឌ្ឍន៍ និងមានលក្ខណៈ **វ.ប.ន.** មានចំនួន ៤៥៧ ដែលកំពុងត្រូវបានអនុវត្ត/បានអនុវត្តដោយស្ថាប័នរាជរដ្ឋាភិបាលក្នុងរយៈពេលប្រាំឆ្នាំ ចុងក្រោយនេះ។ គម្រោង/កិច្ចសហការប្រហែលពីរភាគបី (២/៣) ត្រូវបានធ្វើឡើងក្នុងកម្រិតជាតិ និងមួយ ភាគ បី(១/៣) គឺធ្វើឡើងទាំងកម្រិតតំបន់ និងអន្តរជាតិ។

ទោះបីមានវឌ្ឍនភាព គួរឱ្យកត់សម្គាល់កន្លងមក អនុសាសន៍មួយចំនួនគួរត្រូវយកមកពិចារណាដើម្បី អនុវត្ត និងឈានទៅសម្រេចបាននូវគោលដៅដែលបានកំណត់នៅក្នុងផែនទីបង្ហាញផ្លូវ **វ.ប.ន.** កម្ពុជា ២០៣០៖

- ជាកិច្ចការបន្ទាន់មួយដែលត្រូវធ្វើក្នុងការបង្កើនការយល់ដឹងថែមទៀតអំពីស្នែម និងការចុះឈ្មោះរៀន ជំនាញស្នែមរបស់យុវជននៅឧត្តមសិក្សា ព្រោះផែនទីបង្ហាញផ្លូវ **វ.ប.ន.** កម្ពុជា២០៣០ បានកំណត់ ៥០% ជាគោលដៅ។ គោលដៅនេះចង្អុលបង្ហាញឱ្យដៃគូពាក់ព័ន្ធត្រូវធ្វើការថែមទៀតដើម្បីសម្រេច បានគោលដៅនេះ។
- អគ្គនាយកដ្ឋាន **វ.ប.ន.** នៃក្រសួង **ឧ.វ.ប.ន.** ដែលជាលេខាធិការដ្ឋាននៃ **ក.ជ.វ.ប.ន.** ត្រូវបង្កើតប្រព័ន្ធ គ្រប់គ្រងការស្រាវជ្រាវ និងអភិវឌ្ឍន៍ ដើម្បីប្រមូល តាមដាន និងគ្រប់គ្រងមូលនិធិស្រាវជ្រាវដែល វិនិយោគដោយវិស័យឯកជន និងសាធារណៈ ដើម្បីបានជាបទដ្ឋានមូលដ្ឋាន ក្នុងការសម្រេចឱ្យបាន ១% នៃ **ផ.ស.ស.** ដូចបានកំណត់ក្នុងផែនទីបង្ហាញផ្លូវ **វ.ប.ន.** កម្ពុជា ២០៣០។
- ក្រសួងពាក់ព័ន្ធតម្រូវឱ្យសហការថែមទៀត និងផ្តល់ធាតុចូល/ព័ត៌មាន **វ.ប.ន.** ទៀងទាត់ និងលម្អិត ជូន **ក.ជ.វ.ប.ន.** សម្រាប់ធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនទីបង្ហាញផ្លូវ **វ.ប.ន.** កម្ពុជា២០៣០ និងផែនការ និងការអនុវត្តគោលនយោបាយ **វ.ប.ន.** ផ្សេងៗទៀត។ នេះជាកាតព្វកិច្ច ចាំបាច់យោងតាមព្រះរាជក្រឹត្យលេខ នស/រកត/១០២០/១០៧៣ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ ស្តីពីការបង្កើត **ក.ជ.វ.ប.ន.**។
- អគ្គនាយកដ្ឋាន **វ.ប.ន.** នៃក្រសួង **ឧ.វ.ប.ន.** ជាលេខាធិការដ្ឋាននៃ **ក.ជ.វ.ប.ន.**ត្រូវបង្កើត ប្រព័ន្ធតាម ដាន ត្រួតពិនិត្យ និងវាយតម្លៃជាបន្ទាន់ ដើម្បីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនទី បង្ហាញផ្លូវ **វ.ប.ន.** កម្ពុជា ២០៣០។

# ឯកសារយោង


Asian Development Bank, ADB. (2020). GDP growth rate: Cambodia. Retrieved from *https://www.adb.org/countries/cambodia/main*

DFDL. (2021). Cambodia: Promulgation of the Law on Investment. Accessed at: https://www.dfdl.com/resources/legal-and-tax-updates/cambodia-promulgation-of-the-law-on-investment/

Hang, V. (2020). *Cambodia: current PPP development*. Presentation paper in fourth meeting of the infrastructure and Public-Private Partnership Network of Asia and the Pacific. Phnom Penh: Ministry of Economics and Finance

Hin, P. (2021). Draft PPP law sails through cabinet. Phnom Penh: The Phnom Penh Post

IDEA. (2021). Monitoring Implementation . *Public Program Implementation and Results Monitoring* (p. 4). IDEA.

IDEA. (2021). Result-Based Monitoring and Evaluation Framework within a Result Based Management Approach. (p. 41). IDEA.

IDEA. (2021). Result-Based Monitoring and Evaluation Framework within a Resuts Based Mananagment Approachh. *Public Program Implementation and Results Monitoring* (p. 32). IDEA INTERNATIONAL.

Kuhlmann, S. and Arnold, E. (2001). RCN in the Norwegian Research and Innovation System, Background Report No. 12 in the Evaluation of the Research Council of Norway. Oslo: Royal Norwegian Ministry of Education, Research and Church Affairs.

Marriott, N., & Goyder, H. (2009). *Manual for Monitoring and Evaluating Education Partnerships.* Paris: International Institute of Educational Planning.

MISTI (2020). *Department of Monitoring and Evaluation the policy implementaiton Prakas.* Phnom Penh: MISTI (D/MIE).

MISTI (2021). Cambodia's Science, Technology & Innovation Roadmap 2030. Government Document.

MISTI and UNESCAP (2021). The Science, Technology and Innovation Ecosystem of Cambodia, United Nations Report.

MoEYS (2017). Cambodian higher education roadmap 2030 and beyond. Phnom Penh: MoEYS

MoEYS (2019). *Education Strategic Plan 2019-2023*. Phnom Penh: MoEYs.

MoEYS (2019). The education, youth, and sport performance in the academic year 2015-2016 and goals for the academic year 2017-2018. Annual Education Congress Report. Phnom Penh: MoEYS

MLVT (2021). Statistics of TEVT graduate 2018-2019. Phnom Penh: MoLVT

MOWRAM. (2012). *The MOWRAM Monitoring and Evaluation Manual.* Phnom Penh: The Ministry of Water Resource and Meteorology.

O'Neill, A. (2021, July 22). *Cambodia: Share of economic sectors in the gross domestic product (GDP) from 2010 to 2020*. Retrieved from Statista: https://www.statista.com/statistics/438728/share-of-economic-sectors-in-the-gdp-in-cambodia/

Hong Kong Trade Development Council (HKTDC). (2021). *Cambodia: Market Profile*. Retrieved from: https://research.hktdc.com/en/article/MzIwNzAzMDA1. Accessed on 2021, October 12

RGC (2015). *Industrial Development Policy 2015-2025: market orientation and enabling environment for industrial development*. Phnom Penh: Council of Ministers

RGC (2018). Rectangular Strategy for Growth, Employment, Equity and Efficiency: Building the Foundation Toward Realizing the Cambodia vision 2050, Government document.

RGC (2021). Cambodia Digital Economy and Policy Framework 2021-2035, Government Policy made Supreme National Economic Council.

Samdech Akka Moha Sena Padei Techo HUN SEN (2021). Building Our Sustainable Digital Future, Official Speech, Closing Ceremony of the ASEAN Business and Investment Summit 2021, 21 October 2021.

Taylor, M. Z. (2016). The Politic of Innovation: Why some countries are better than others in Science and Technology, Published in the United States of America by Oxford University Press, 198 Madison Avenue, New York, NY 10016, United States of America.

UNCTAD. (2021, July 22). *General Profile: Cambodia*. Retrieved from UNCTADSTAT: https://unctadstat.unctad.org/countryprofile/generalprofile/en-gb/116/index.html

UNDP (2020). *Adaptation and adoption of industry 4.0 in Cambodia*. Phnom Penh: UNDP & University of Cambridge

United Nations Economic and Social Commission for Asia and the Pacific, UN-ESCAP. (2021). *Ecosystem of Science, Technology, and Innovation in Cambodia*. Bangkok: UN-ESCAP

Voleak, S., 2021. Non Formal Education Department. [online] Moeys.gov.kh. Available at: <http://www.moeys.gov.kh/en/nfe/non-formal-education-department.html#.YZ1N9C0RrUo> [Accessed 23 November 2021].

World Bank Group. (2021). The Impact Of The Covid-19 Pandemic On Learning And Earning In Cambodia In Cambodia Economic Update: The World Bank

World population Review. (2021). Retrieved from Cambodia Population: https://worldpopulationreview.com/countries/cambodia-population



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍